នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក-កសចស/អបជ ៥៦ |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Apr-2019, 13:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359)**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jim BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង០០៤/២ ទាំងអស់**

## មាតិកា

I. សេចក្តីផ្តើម ........ 3

II. ប្រវត្តិនីតិវិធី និងច្បាប់ជាធរមាន ........ 4

III. សេចក្តីសន្និដ្ឋាន ........ 5

ក. ស.ច.ស.ជ មានភាតព្វកិច្ចក្នុងការកំណត់ផ្លូវច្បាប់ឲ្យបានត្រឹមត្រូវលើគ្រប់អង្គហេតុ ទាំងអស់ដែលបានប្តឹងទៅគាត់ ប៉ុន្តែគាត់ខកខានមិនបានធ្វើដូច្នេះ ........ 5

ខ. កំហុសផ្នែកច្បាប់ និងអង្គហេតុរបស់ ស.ច.ស.ជ ធ្វើឲ្យខូចសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ ........ 10

១. ដីកាសម្រេចលើកលែងចោទប្រកាន់បានផ្តល់ទម្ងន់ទៅលើបញ្ហាថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់ 11

២. ការអនុវត្តច្បាប់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ មិនស៊ីសង្វាក់គ្នា ទៅនឹងយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក ........ 20

គ. ស.ច.ស.ជ បានបកស្រាយច្បាប់ដោយមិនត្រឹមត្រូវ នៅពេលដែលគាត់បានសន្និដ្ឋានថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់" ដែលនាំឲ្យគាត់អនុវត្តច្បាប់មិនបាន ត្រឹមត្រូវ ........ 25

ឃ. ដីកាសម្រេចលើកលែងចោទប្រកាន់បានវាយតម្លៃដោយមិនសមហេតុមិនសមផល នៅលើតំណាងសំខាន់ៗ ដែលជាកំហុសអង្គហេតុមួយដ៏សំខាន់ដើម្បីសម្រេចថា អោ អាន មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ........ 27

ង. ការវិភាគអង្គហេតុរបស់ អោ អាន មិនត្រឹមត្រូវ និងមិនគួរឲ្យជឿជាក់បាន ........ 31

១. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ពាក់ព័ន្ធនឹងតួនាទីរបស់ អោ អាន នៅក្នុងការចាប់ខ្លួន និងការសម្លាប់ចោល មិនសមហេតុផល ........ 31

២. ការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មក្នុងភូមិភាគកណ្តាល ........ 35

៣. តួនាទីរបស់ អោ អាន នៅថ្នាក់ភូមិភាគ ........ 38

ច. សចសជ មានកំហុសអង្គច្បាប់ដោយខកខានមិនបានវាយតម្លៃភាពធ្ងន់ធ្ងរ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចោទប្រកាន់ ........ 40

ឆ. គោលជំហររបស់ សពអ លើដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា គោរពតាមកិច្ចព្រមព្រៀង អ.វ.ត.ក គោលបំណងរបស់អ្នកតាក់តែងច្បាប់ វិធានផ្ទៃក្នុង និងយុត្តិសាស្ត្រ អ.វ.ត.ក ........ 44

IV. ដំណោះស្រាយដែលស្នើឡើង ........ 47

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយដែលចោទប្រកាន់ អោ អាន ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងឱ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") ក៏បានចេញដីកាដំណោះស្រាយដោយច្រានចោលបទចោទទាំងអស់ប្រឆាំងនឹង អោ អាន ដោយសំអាងលើមូលដ្ឋានថា គាត់មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ("ដីកាសម្រេចលើកលែងចោទប្រកាន់")[2]។ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់នេះ ដោយផ្អែកលើមូលដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកលើកំហុសអង្គហេតុ និងអង្គច្បាប់ ដែលធ្វើឱ្យសេចក្តីសម្រេចលែងមានសុពលភាព ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")[3]។

2. នៅក្នុងចម្លើយតប[4] អោ អាន ជំទាស់ដោយមិនត្រឹមត្រូវថា ដីកាសម្រេចលើកលែងចោទប្រកាន់តម្រូវឱ្យមានយុត្តិកម្មតិចតួចជាងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ និងថា ស.ច.ស.ជ បានពិចារណាយ៉ាងត្រឹមត្រូវអំពីការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជារបស់ថ្នាក់លើ ព្រមទាំងថា ស.ច.ស.ជ មិនបានសម្រេចថា ឌុច "គឺជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់" នោះទេ។ លើសពីនេះទៀត ចម្លើយតបរបស់ អោ អាន យកអំណះអំណាងពីមុនរបស់ខ្លួនទាក់ទងនឹងភាពជឿជាក់បានរបស់ ប្រាក់ យុត និងតួនាទី ព្រមទាំងការទទួលខុសត្រូវរបស់ អោ អាន ហើយធ្វើមិនដឹងមិនឮអំពីកំហុសជាមូលដ្ឋានទាក់ទងនឹងអំពើប្រល័យពូជសាសន៍។ ចុងក្រោយ ចម្លើយ

---

[1] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) KH 01588970-77។

[2] *ឯកសារ* **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ (ដីកាសម្រេចលើកលែងចោទប្រកាន់) កថាខណ្ឌ ៥៥៤-៥៥៥។

[3] *ឯកសារ* **D359/3/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359), ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")។

[4] *ឯកសារ* **D359/3/4** ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359), ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ("ចម្លើយតបរបស់ អោ អាន")។

តបវាយប្រហារលើដំណើរការដែលសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជ្រើសរើសសម្រាប់ដោះស្រាយលើការខ្វែងយោបល់គ្នារបស់ពួកគេលើបញ្ហាយុត្តាធិការបុគ្គល តាមរយៈការព្យាយាមមិនជោគជ័យក្នុងការបង្ហាញពីភាពខុសគ្នារវាងដំណើរការទាំងនោះដោយគ្មានភាពខុសគ្នាជាក់ស្តែងទេ។ ដូច្នេះ ស.ព.អ សូមធ្វើការឆ្លើយតបដូចខាងក្រោម។

## II. ប្រវត្តិនីតិវិធី និងច្បាប់ជាធរមាន

3. ស.ព.អ សូមបញ្ចូលតាមរយៈការយោងទៅប្រវត្តិនីតិវិធីដែលមានក្នុងឧបសម្ព័ន្ធ I នៃបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[5] និងប្រវត្តិនៃសេចក្តីថ្លែងសំអាងឧទ្ធរណ៍ដែលមានលើកឡើងខាងលើ។

4. លើសពីនេះទៀត នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានសម្រេចពន្យារពេលវេលា និងបន្ថែមចំនួនទំព័រកំណត់ សម្រាប់ការឆ្លើយតបរបស់ភាគីនានាទៅនឹងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងពីរ ដោយបានណែនាំឲ្យភាគីដាក់ការឆ្លើយតបរបស់ខ្លួនដែលមានចំនួន ៣០ ទំព័រ តែមួយភាសា ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងសំណៅបកប្រែសម្រាប់ចម្លើយតបដែលពួកគាត់កំពុងតែធ្វើការឆ្លើយតប[6]។ ចម្លើយតបរបស់អោ អាន បានដាក់ជាភាសាអង់គ្លេសជាមុន ដោយសំណៅបកប្រែជាភាសាខ្មែរត្រូវបានដាក់តាមក្រោយនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩[7] ធ្វើឲ្យការឆ្លើយតបនេះ ត្រូវនឹងថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

5. ច្បាប់ជាធរមាន មានចែងក្នុងផ្នែកពាក់ព័ន្ធខាងក្រោម។

---

[5] ឯកសារ **D359/3/1.2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន, ឧបសម្ព័ន្ធ I: ប្រវត្តិនីតិវិធី, ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

[6] ឯកសារ **D360/5/3** សាលដីកាលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ សម្រាប់ចម្លើយតបនិងការឆ្លើយតបទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង០០៤/២, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩, KH 01599765។

[7] សេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិកពីមន្ត្រីទទួលបន្ទុកសំណុំរឿង, ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩, ម៉ោង 4:11 រសៀល។

## III. សេចក្តីសន្និដ្ឋាន

### ក. ស.ច.ស.ជ មានកាតព្វកិច្ចក្នុងការកំណត់ផ្លូវច្បាប់ឲ្យបានត្រឹមត្រូវលើគ្រប់អង្គហេតុ ទាំងអស់ដែលបានប្តឹងទៅគាត់ ប៉ុន្តែគាត់ខកខានមិនបានធ្វើដូច្នេះ

6. អោ អាន តវ៉ាទាំងមិនត្រឹមត្រូវថា ស.ព.អ បានបញ្ចូលលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៃការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ និងលក្ខខណ្ឌសម្រាប់ដីកាសម្រេចលើកលែងចោទប្រកាន់ ។ គាត់តវ៉ាថា ដីកាសម្រេចលើកលែងចោទប្រកាន់តម្រូវឱ្យមានសំអាងហេតុតិចជាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងថា ដូច្នេះ ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ បានបំពេញតាមលក្ខខណ្ឌតិចតួចនេះ[8]។ យ៉ាងណាក៏ដោយ ច្បាប់ និងយុត្តិសាស្ត្រជាធរមាន មិនគាំទ្រចំពោះអំណះអំណាងរបស់គាត់នេះទេ។

7. ទីមួយ ដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ទាំងពីរគឺជាដីកាដំណោះស្រាយ ហើយមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចគ្នា។ មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ការស៊ើបសួរត្រូវបានបិទតាមដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់[9]។ ដោយមិនគិតថា តើសេចក្តីសម្រេចនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះឬអត់នោះទេ ក្រមនេះបានចែងថា "ដីកាដំណោះស្រាយ ជានិច្ចកាលត្រូវតែមានសំអាងហេតុ"[10]។ ប្រភពនានាពីប្រទេសបារាំងដែល អោ អាន បានពឹងផ្អែកដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនគ្រាន់តែបង្ហាញថា ដីកាលើកលែងចោទប្រកាន់ត្រូវតែមានសំអាងហេតុ មិនមែនថា តម្រូវឱ្យមានសំអាងហេតុតិចនោះទេ[11]។

---

[8] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ៧-១៣។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ និងបានបកប្រែជាភាសាអង់គ្លេសនៅខែកញ្ញា ឆ្នាំ២០០៨ ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") មាត្រា ២៤៧។ សូមកត់សំគាល់ថា ក្នុងក្រមនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានគេហៅថា "non-suit order"។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ២៤៧។

[11] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កំណត់សំគាល់ជើងទំព័រ ២៦។ ជាឧទាហរណ៍ សៀវភៅដែលពិភាក្សាអំពីនីតិវិធីបារាំងចែងថា: "L'ordonnance de non-lieu est motivée en fait ou en droit." ដែលតាមការបកប្រែក្នុងន័យមិនតឹងមានន័យថា "ដីកាលើកលែងចោទប្រកាន់ត្រូវមានសំអាងហេតុនៅក្នុងអង្គហេតុ ឬអង្គច្បាប់"។ *សូមមើល* ឯកសារ

8. ដីកាសម្រេចលើកលែងចោទប្រកាន់ បានពឹងផ្អែកលើការសម្រេចមួយថា ជនសង្ស័យ ឬជនត្រូវចោទ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលមានន័យថា មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ឬជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ ជាដីកាសម្រេចដែលត្រូវតែពិចារណាលើទម្ងន់នៃឧក្រិដ្ឋកម្មដែលបានប្តឹងទៅ ស.ច.ស និងវាយតម្លៃចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ឬជនត្រូវចោទរូបនោះ[12]។ ក្នុងសំណុំរឿង ០០៤/១ ស.ច.ស បានចេញដីកាសម្រេចលើកលែងចោទប្រកាន់រួម ដោយសម្រេចថា គ្មានយុត្តាធិការបុគ្គល ដោយផ្អែកការវាយតម្លៃរបស់ខ្លួនលើ ការសម្រេចនានាដែលមានលក្ខណៈកំហិតតែទីតាំង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប៉ុណ្ណោះ មិនមែនការចោទប្រកាន់ផ្នែកអង្គហេតុទាំងអស់ដែលបានប្តឹងទៅពួកគាត់[13]។ អ.ប.ជ បានសម្រេចជាឯកច្ឆន្ទយ៉ាងដូច្នេះថា៖

> ការសម្រេចថាពុំមានយុត្តាធិការនោះ មិនមែនមិនអាចពិនិត្យឡើងវិញបាននោះឡើយ ហើយអង្គបុរេជំនុំជម្រះ ដែលជាអង្គជំនុំជម្រះពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ ប្រាកដជាអាចពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែប

---

**D359/3/4.1.4** Guery & Chambon (ed.), *Droit et pratique de l'instruction préparatoire*, ២០១៨-២០១៩, វាក្យខណ្ឌ ៣, FR 01601006។ ស្រដៀងនេះ ករណីដែលបានលើកយោងនៅតុលាការបារាំង Cour de Cassation (តុលាការឧទ្ធរណ៍) ដែលពាក់ព័ន្ធនឹងអ្នកប្តឹងឧទ្ធរណ៍ម្នាក់តវ៉ាអំពីដីកាសម្រេចលើកលែងចោទប្រកាន់ដែលគ្មានសំអាងហេតុគ្រប់គ្រាន់។ តុលាការ Cour de Cassation បានតម្កល់សេចក្តីសម្រេចរបស់របស់អង្គជំនុំជម្រះ "Chambre de l'instruction" ដោយសម្រេចថា "aux motifs qu'au cours d'une longue instruction de nombreuses recherches ont été effectuées et toutes les pistes successivement envisagées ou proposées ont été exploitées avec attention et minutie" ដែលតាមការបកប្រែក្នុងន័យមិនតឹងរ៉ឹង មានន័យថា "បន្ទាប់ពីកិច្ចស៊ើបសួរដ៏វែង មានការស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើង ហើយជម្រើសដែលអាចធ្វើបាននានាត្រូវបានលើកឡើងដោយមានការយកចិត្តទុកដាក់ជាខ្លាំង និងយ៉ាងល្អិតល្អន់" (សូមមើល ឯកសារ **D359/3/4.1.5** Cass. Crim., ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨, លេខ 17-84665, FR 01601013។

[12] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ), ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្តីពិចារណារបស់ អ.ប.ជ ចំពោះ អ៊ឹម ចែម"), កថាខណ្ឌ ១៤២ (ចៅក្រម Beauvallet និង Baik) ដោយសន្និដ្ឋាន "ថា ជារួម សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការកំណត់ផ្លូវច្បាប់ឲ្យបានត្រឹមត្រូវទាក់ទងនឹងការបោសសម្អាតនៅភូមិភាគពាយ័ព្យ ពិចារណាអំពីស្ថានទម្ងន់បទឧក្រិដ្ឋ និងវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅក្នុងនោះ"។

[13] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ចំពោះ អ៊ឹម ចែម, កថាខណ្ឌ ១២, ១១៦, ១២៨-១២៩, ១៣៩, ១៤១។

នេះ *រួមទាំង* សេចក្ដីសន្និដ្ឋានទាំងឡាយណាពាក់ព័ន្ធនឹងអត្ថិភាពនៃឧក្រិដ្ឋកម្ម ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អ៊ឹម ចែម”[14]។

9. អោ អាន ទទួលស្គាល់ការសម្រេចនេះ ប៉ុន្តែតវ៉ាថា “ស.ច.ស.ជ គ្មានកាតព្វកិច្ចផ្លូវច្បាប់នៅក្នុងការសម្រេចផ្នែកយុត្តាធិការរបស់គាត់” ដោយផ្អែកលើអត្ថិភាពនៃឧក្រិដ្ឋកម្ម ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន *“ឲ្យហួសពី* ការពិចារណាដ៏ត្រឹមត្រូវ និងពាក់ព័ន្ធណាមួយផ្សេងទៀត”ឡើយ និងថាអ្វីៗទាំងអស់ដែល ស.ច.ស.ជ ត្រូវធ្វើគឺការផ្ដល់សំអាងហេតុឲ្យបានគ្រប់គ្រាន់សម្រាប់ការសម្រេចនានាដែលថាតុលាការពុំមានយុត្តាធិការបុគ្គលលើ អោ អាន[15]។ ចំណុចនេះខុសហើយ។ ស.ច.ស ត្រូវតែធ្វើការសម្រេចលើគ្រប់បទឧក្រិដ្ឋទាំងអស់ដែលបានប្ដឹងទៅពួកគាត់ និងត្រូវថ្លឹងថ្លែងចំពោះស្ថានទម្ងន់នៃបទឧក្រិដ្ឋទាំងនោះ ព្រមទាំងការទទួលខុសត្រូវរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ ដើម្បីផ្ដល់សេចក្ដីសម្រេចមួយដែលមានសំអាងហេតុលើយុត្តាធិការបុគ្គល[16]។ បើគ្មានការសម្រេចដូច្នេះទេ អ.ប.ជ មិនអាចពិនិត្យមើលឡើងវិញលើសេចក្ដីសម្រេចអំពីយុត្តាធិការបុគ្គលបានឡើយ។ ទាំង ស.ច.ស និងទាំង អ.ប.ជ សុទ្ធតែបានទទួលស្គាល់ថា *“មានកាតព្វកិច្ច* ក្នុងការធ្វើសេចក្ដីសម្រេច*នៅក្នុងដីកាដំណោះស្រាយ* ទាក់ទងនឹងអង្គហេតុ*នីមួយៗ* ដែល[ស.ច.ស] ត្រូវបានប្ដឹងយ៉ាងត្រឹមត្រូវ”[17]។ លើសពីនេះទៀត

---

[14] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ចំពោះ អ៊ឹម ចែម, កថាខណ្ឌ ២៦ (សង្កត់ន័យដើម)។

[15] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ៩-១៣ (សង្កត់ន័យដើម)។

[16] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ចំពោះ អ៊ឹម ចែម, កថាខណ្ឌ ១៤២, ១៥៥, ១៧២, ១៧៤, ១៧៦, ១៨៨-១៨៩, ១៩៧, ២០៣-២០៤, ២០៧, ២១៣ (ចៅក្រម Beauvallet និង Baik)។

[17] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ ១០ (សង្កត់ន័យដើម), ផ្នែកសម្រេចសេចក្ដី [“អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត [...] ថ្លែងថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតនឹងធ្វើការសម្រេចទាក់ទងនឹងអង្គហេតុទាំងអស់នេះ និងការកំណត់បទចោទពាក់ព័ន្ធដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (រួមទាំងអំពើប្រល័យពូជសាសន៍ និងបទល្មើសផ្សេងទៀតតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦”] ទោះជាត្រូវចោទប្រកាន់បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬត្រូវចេញដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះអង្គហេតុមួយផ្នែកឬទាំងអស់ក្ដី”]។ សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេចអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ២៩, ៣២-៣៩, ៥៧, ១១៥។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ចំពោះ

គ្មានភាពខុសគ្នាឡើយទោះបីជានៅក្នុងដីកាដំណោះស្រាយនោះ មានដីកាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ក្តី លក្ខខណ្ឌតម្រូវគឺដូចគ្នា[18]។

10. ករណីព្រហ្មទណ្ឌនៃប្រទេសបារាំងពីរករណី ដែលជាមគ្គុទេសក៍ដ៏មានប្រយោជន៍ដោយសារតែនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានពឹងផ្អែកស្ទើរតែទាំងស្រុងលើប្រព័ន្ធច្បាប់បារាំងនោះ បង្ហាញឱ្យឃើញទៀតថា ចៅក្រមស៊ើបសួរមានភារកិច្ចចេញដីកាសម្រេចដែលប្រកាសអំពីអង្គហេតុ *ទាំងអស់* ដែលបានប្តឹង[19]។ យុត្តិសាស្ត្ររបស់តុលាការ ICC ក៏គាំទ្រចំពោះគោលការណ៍ដែលថា ចៅក្រមត្រូវតែផ្តល់ការសម្រេចផ្លូវច្បាប់ត្រឹមត្រូវលើគ្រប់ការចោទប្រកាន់ទាំងអស់នៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់។ សេចក្តីសម្រេចនានារបស់អង្គបុរេជំនុំជម្រះនៃតុលាការ ICC បានធ្វើការពិចារណាយ៉ាងល្អិតល្អន់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលរបស់ជនសង្ស័យម្នា

---

អ៊ឹម ចែម, កថាខណ្ឌ ១១៦ (ចៅក្រម Beauvallet និង Baik)។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាសម្រេចលើបណ្តឹងសារទុក្ខ, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា ឌុច"), កថាខណ្ឌ៨០ [ពិភាក្សាអំពីវិសាលភាពដ៏ចង្អៀតឬសហេតុអំពីការពិនិត្យមើលឆន្ទានុសិទ្ធិរបស់ ស.ច.ស និងសហព្រះរាជអាជ្ញា ដោយឈរមូលហេតុថា ពួកគាត់បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនស្មោះត្រង់ ឬបានប្រើប្រាស់សាលក្រមអាជីពដែលមិនត្រឹមត្រូវ]។ ជាការពិតណាស់ ការពិនិត្យមើលអំពីការបំពានឆន្ទានុសិទ្ធិដូចដែលបានចោទ មិនអាចដឹកនាំធ្វើបានឡើយនៅពេលដែល ស.ច.ស បានទាត់ចោលអង្គហេតុនានាដោយគ្មានការផ្តល់នូវការកំណត់ផ្លូវច្បាប់ណាមួយ ឬសំអាងហេតុនោះ។

[18] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ៨-១២។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ចំពោះ អ៊ឹម ចែម, កថាខណ្ឌ ១២៩, ១៤១-១៤២, ១៥៥, ១៧២, ១៧៤, ១៧៦, ១៨៨-១៨៩, ១៩៧, ២០៣-២០៤, ២០៧, ២១៣ (ចៅក្រម Beauvallet និង Baik), ទាំងអស់នេះបង្ហាញឱ្យឃើញថា ស.ច.ស តម្រូវដោះស្រាយឱ្យបានច្បាស់លាស់ និងធ្វើការកំណត់ផ្លូវច្បាប់ឱ្យបានត្រឹមត្រូវទាក់ទងនឹងឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្តឹងមកខ្លួន ពិចារណាអំពីស្ថានទម្ងន់នៃបទឧក្រិដ្ឋ និងវាយតម្លៃអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ។

[19] Cass. Crim., ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧, លេខ 76-91442, ទំព័រ ៤ ["Le juge d'instruction avait l'obligation d'instruire, puis de statuer par une ordonnance de règlement sur l'ensemble des faits […] Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi." ការបកប្រែក្រៅផ្លូវការ: "សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេត រួចហើយចេញដីកាសម្រេចលើគ្រប់អង្គហេតុទាំងអស់។ […] ចៅក្រមមានកាតព្វកិច្ចប្រកាសអំពីអង្គហេតុទាំងអស់ដែលបានប្តឹងមកគាត់យ៉ាងទៀងទាត់"]។ Cass. Crim., ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៤, លេខ 03-85983, ទំព័រ ៣ ["le juge d'instruction n'a pas statué, comme il en a le devoir, dans son ordonnance de renvoi, sur tous les faits dont il est saisi". ការបកប្រែក្រៅផ្លូវការ: "សហចៅក្រមស៊ើបអង្កេតមិនធ្វើការសម្រេចនៅក្នុងដីកាដំណោះស្រាយរបស់គាត់ តាមកាតព្វរបស់គាត់ លើគ្រប់អង្គហេតុទាំងអស់ដែលបានប្តឹងមកគាត់នោះទេ"]។

ក់ៗលើអង្គហេតុដែលបានចោទប្រកាន់ទាំងអស់ ទោះបីជាចៅក្រមបានសម្រេចមិនតម្កល់បទចោទទាំងនោះប្រឆាំងនឹងជនសង្ស័យនោះក៏ដោយ[20]។

11. ផ្ទុយមកវិញ ដីកាលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/២ ពុំមានសេចក្តីសន្និដ្ឋានផ្លូវច្បាប់ជាចុងក្រោយទាក់ទងនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនីមួយៗដែលបានប្តឹងទៅ ស.ច.ស[21]ទេ។ អោ អាន បានរាប់ចំនួនកថាខណ្ឌដែលមានលើកឡើងអំពីបញ្ហាផ្សេងៗជាច្រើនក្នុងការប៉ុនប៉ងបង្ហាញឲ្យឃើញថា ស.ច.ស.ជ បានផ្តល់សំអាងហេតុគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសម្រេចផ្នែកយុត្តាធិការរបស់គាត់[22] ប៉ុន្តែ វាគ្រាន់តែជាការពិភាក្សាដែលមិនបានបំពេញទៅនឹងកាតព្វកិច្ចសំខាន់ក្នុងការធ្វើសេចក្តីសម្រេចផ្លូវច្បាប់ដ៏ត្រឹមត្រូវដូចបានរៀបរាប់ខាងលើតែប៉ុណ្ណោះ សម្រាប់ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់ ស្ថានទម្ងន់របស់វា និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មនោះ[23]។

12. ជាចុងក្រោយ អំណះអំណាងរបស់ អោ អាន ដែលលើកយោងអំពីការសន្សំសំចៃរបស់តុលាការធ្វើជាយុត្តិកម្មក្នុងការផ្តល់សំអាងហេតុតិចតួចក្នុងដីកាសម្រេចលើកលែងចោទប្រកាន់នោះ គឺជារឿងខុស[24]។ គាត់ផ្អែកការអះអាងរបស់គាត់លើសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ ដែលពាក់ព័ន្ធនឹង "ញត្តិស្នើសុំមួយដែលមានលក្ខណៈស្រដៀងគ្នាជាខ្លាំង ទៅនឹងញត្តិដែលធ្លាប់មាននៅចំពោះមុខអង្គបុរេជំនុំជម្រះដែរ"[25]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច

---

[20] *សូមមើល ជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Ruto នឹងគូកន.,* ICC-01/09-01/11, សេចក្តីសម្រេចលើការបញ្ជាក់អះអាងចំពោះបទចោទ អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម, អង្គបុរេជំនុំជម្រះទី II, ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២, កថាខណ្ឌ២២, ១១៣-១៦០, ២២៤-២៩២, ២៩៣-៣០០។ *រដ្ឋអាជ្ញា ទល់នឹង Mbarushimana*, ICC-01/04-01/10, សេចក្តីសម្រេចលើការបញ្ជាក់អះអាងចំពោះបទចោទ, អង្គបុរេជំនុំជម្រះទី I, ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១, កថាខណ្ឌ៦-៨, ១០៨-២៣៩, ២៩១-៣៤០។ *រដ្ឋអាជ្ញា ទល់នឹង Abu Garda*, ICC-02/05-02/09, សេចក្តីសម្រេចលើការបញ្ជាក់អះអាងចំពោះបទចោទ, អង្គបុរេជំនុំជម្រះទី I, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១០, កថាខណ្ឌ២១-២៤, ៩៧-២៣៦។

[21] តាមពិត ដីកាសម្រេចលើកលែងចោទប្រកាន់បានចែងយ៉ាងច្បាស់ថា "មិនធ្វើការកំណត់បទល្មើស ឬធ្វើចំណាត់ថ្នាក់អំពីទម្រង់នៃការទទួលខុសត្រូវទេ"។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២។

[22] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១១។

[23] *សូមមើលផងដែរ* កិច្ចពិភាក្សានៅក្នុងឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ១៥, ១៧-៣១។

[24] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១២។

[25] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ២៥។

ថា ហេតុដូច្នេះ ខ្លួននឹង "មិនចេញសេចក្តីសម្រេចវែងទេ ក្នុងកាលៈទេសៈដែលខ្លួនមិនអាចរកបាន មូលហេតុសមហេតុផលដើម្បីងាកចេញពីការវិភាគរបស់អង្គបុរេជំនុំជម្រះ និងដែលមានលទ្ធផល ស្របគ្នា"[26]។ យ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ មិនស្រដៀងគ្នាខ្លាំង" ទៅនឹងអ្វីមួយដែលធ្លាប់វិវាទកាលពីមុននោះទេ ហើយក៏មិនបានធ្វើតាមការ វិភាគពីមុនណាមួយ ឬក៏ស្របទៅនឹងលទ្ធផលដែលគេធ្លាប់បានធ្វើកន្លងមកនោះដែរ។ ក្រៅពី ការបង្ហាញថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវការតែយុត្តិកម្មបន្តិចបន្តួច សេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានសង្កត់ធ្ងន់ទៅលើរបៀបថាតើ ការកំណត់ផ្លូវច្បាប់ ត្រឹមត្រូវមួយមានសារសំខាន់យ៉ាងណាលើការចោទប្រកាន់នីមួយៗប៉ុណ្ណោះ សម្រាប់ការសម្រេច ពេលអនាគតដែលត្រូវតែពិនិត្យ ឬចង់អនុវត្តតាមដីកាសម្រេចលើកលែងចោទប្រកាន់។

## ខ. កំហុសផ្នែកច្បាប់ និងអង្គហេតុរបស់ ស.ច.ស.ជ ធ្វើឱ្យខូចសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់

13. ផ្ទុយពីការអះអាងរបស់ អោ អាន[27] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ បានកំណត់យ៉ាងច្បាស់ លាស់នៅលើផ្នែកនានានៃដីកាសម្រេចលើកលែងចោទប្រកាន់ដែល ស.ច.ស.ជ មានកំហុស តាមរយៈការផ្តល់ស្ថានទម្ងន់ច្រើនហួសហេតុទៅលើបញ្ហារបស់ថ្នាក់លើ ការបង្ខិតបង្ខំ និងការគាប សង្កត់នៅក្នុងការវាយតម្លៃរបស់គាត់អំពីយុត្តាធិការបុគ្គល[28]។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ បាន ពិភាក្សាពីរបៀបថាតើ ស.ច.ស.ជ បានពឹងផ្អែកលើលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដែលខុសថា ប្រសិន បើគាត់រកឃើញថា សកម្មភាពព្រហ្មទណ្ឌរបស់ អោ អាន មិនហួសពីវិសាលភាពនៃសិទ្ធិអំណាច ផ្លូវការរបស់ខ្លួនទេ នោះវានឹងបន្ថយការទទួលខុសត្រូវរបស់គាត់ ដែលហាក់ដូចជាតម្រូវឱ្យបុគ្គល នោះត្រូវតែហួសពីវិសាលភាពនោះ ដើម្បីឱ្យបុគ្គលរូបនោះធ្លាក់ក្នុងប្រភេទនៃជនម្នាក់នៃ "ជនទាំង

---

[26] សំណុំរឿង ០០២-ឯកសារ **E100/6** សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ២៦។

[27] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១៤-១៦ [ថ្លែងថា ស.ព.អ ខកខានមិនបានបង្ហាញអត្តសញ្ញាណ កំហុសអង្គហេតុ អង្គច្បាប់ ឬចន្ទានុសិទ្ធិណាមួយទេ]។

[28] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កំណត់សំគាល់ជើងទំព័រ៩៣-៩៥, ១០១-១០៣, ១០៥-១០៦, ១៣៤-១៣៥។

ឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”[29]។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ក៏បានលម្អិតពីរបៀបដែលដីកាសម្រេចលើកលែងចោទប្រកាន់មិនស្របនឹងច្បាប់ដែលបានអនុវត្តផងដែរ ទាក់ទងនឹងបញ្ហារបស់ថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់នៅពេលដែលយុត្តាធិការបុគ្គលត្រូវបានវាយតម្លៃនៅក្នុងសំណុំរឿង ០០១ សម្រាប់ ឌុច[30]។

## ១. ដីកាសម្រេចលើកលែងចោទប្រកាន់បានផ្តល់ទម្ងន់ទៅលើបញ្ហាថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់

14. អោ អាន អះអាងថា គឺជារឿងត្រឹមត្រូវដែល ស.ច.ស.ជ បានផ្តល់ទម្ងន់ដ៏សំខាន់ទៅលើកត្តានានាដូចជា បញ្ហាថ្នាក់លើ ការបង្ខិតបង្ខំ និងការគាបសង្កត់នៅក្នុងការវាយតម្លៃអំពីថាតើ អោ អាន ធ្លាក់ចូលក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់ ដោយសារតែ ស.ច.ស.ជ មិនជាប់កាតព្វកិច្ចដោយសារការកម្រិតដូចគ្នា ដែលនឹងត្រូវបង្ហាញអំពីការប្រើប្រាស់ការការពារខ្លួនបែបនេះនៅពេលសវនាការទេ[31]។ យ៉ាងណាមិញ យោងតាមយុត្តិសាស្ត្រដែលបានបង្កើតបញ្ហាថ្នាក់លើមិនគួរទទួលបានទម្ងន់បែបនេះទេ[32]។ លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) ធ្លាប់បានសម្រេចថា អត្ថិភាពនៃបញ្ហាថ្នាក់លើមិនបានច្រានចោលការសម្រេចមួយថា ជនសង្ស័យម្នាក់ គឺជាជនម្នាក់នៃជនទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត” នោះឡើយ៖

> ចាប់ផ្តើមធ្វើការវាយតម្លៃប្រហាក់ប្រហែលនេះ ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌ [..] នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ [...] គឺមានន័យស្មើនឹងការអនុញ្ញាតឲ្យមាន

[29] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, វាក្យខណ្ឌ IV.ខ.៣។

[30] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, វាក្យខណ្ឌ IV.ខ.៤។ *សូមមើលផងដែរ* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង” ឬ “វិធាន”), វិធាន ២១(១)(ខ) ដែលចែងថា: “បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត”។

[31] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១៦។

[32] នៅក្នុងចំណុចជាច្រើន ដីកាសម្រេចលើកលែងចោទប្រកាន់បានអះអាងថា អោ អាន គ្មានជម្រើសក្នុងការអនុវត្តគោលនយោបាយរបស់ថ្នាក់លើ។ *សូមមើល* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កំណត់សំគាល់ជើងទំព័រ៩៣-៩៥ និង ១០១-១០៣ *ដោយលើកយោង* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤៩៦, ៤៩៩-៥០១, ៥១០-៥១១, ៥១៩, ៥២៨, ៥៣៣, ៥៣៥, ៥៤៦-៥៤៧, ៥៥២-៥៥៣។

ការការពារខ្លួនដោយប្រយោលចំពោះបញ្ជាថ្នាក់លើ ហើយផ្ទុយនឹងបទប្បញ្ញត្តិនានា ដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងមាត្រា២៩ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ។[33]

15. ចាប់តាំងពីពេលដែលធម្មនុញ្ញទីក្រុងឡុងដ៍ បានបង្កើតតុលាការព្រហ្មទណ្ឌយោធានៅ Nuremberg មក វាបានធ្វើឱ្យគេកាន់តែយល់យ៉ាងច្បាស់ថា នៅក្រោមច្បាប់ទម្លាប់អន្តរជាតិ ជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិធ្វើឡើងតាមបញ្ជាថ្នាក់លើ មិនមែនមិនជាប់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ[34]។ ទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងទាំងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សុទ្ធតែបានចែងថា បញ្ជាខុសច្បាប់ពីថ្នាក់លើ មិនអាចជួយជនសង្ស័យឱ្យគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ[35]។ មានករណីជាច្រើនធ្លាប់បានសម្រេចថា មានកាតព្វកិច្ច *មិនគោរព* បញ្ជាខុសច្បាប់មួយ[36] ហើយក៏មានតុលាការខ្លះធ្លាប់បានសម្រេច ថាជន

[33] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ៦២។

[34] ដូចបានពិភាក្សាក្នុងឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កំណត់សំគាល់ជើងទំព័រ៣៤ ជាពិសេសប្រភពនានាដែលបានយោងនៅក្នុងកំណត់សំគាល់ជើងទំព័រ ៩៩។

[35] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលមានការដាក់បញ្ចូលនូវវិសោធនកម្មនានាដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦), ("ច្បាប់ អ.វ.ត.ក"), មាត្រា ២៩(៤) ["ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ"។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៥៦) *ដែលបានប្រកាសឱ្យប្រើ* ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៥៥ (ក្រម លេខ ៩៣៣ នស) ("ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦") មាត្រា ១០០ ["ក្នុងករណីដែលសេចក្តីបង្គាប់ជាអនិត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូបនោះ ចៅក្រមត្រូវថ្លឹងមើលតាមការណ៍គួរ នូវភាពនៃការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការណ៍នោះ" (បកប្រែក្រៅផ្លូវការ)"]។

[36] ដូចបានពិភាក្សាក្នុងឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កំណត់សំគាល់ជើងទំព័រ៩៩ *លើកយោងច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់* Cassese ទំព័រ ២៣៧។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង* *Erdemović,* IT-96-22-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៧, មតិដាច់ដោយឡែកនិងជំទាស់របស់ចៅក្រម Cassese, កថាខណ្ឌ ១៥ ("មតិជំទាស់របស់ Cassese ក្នុងរឿងក្តី *Erdemović*")។ *រដ្ឋអាជ្ញា ទល់នឹង Mrkšić & Šljivančanin,* IT-95-13/1-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩, កំណត់សំគាល់ជើងទំព័រ ៣៣១។

ត្រូវចោទដែលធ្វើតាមបញ្ជាបែបនេះត្រូវបានច្រានចោលជាមុនពីការទាមទារការបន្ធូរបន្ថយទោសណាមួយផងដែរ[37]។

16. ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់ ឌុច ទាក់ទងនឹងបញ្ជាថ្នាក់លើ ដោយបានសម្រេចថា គាត់ "បានដឹងថា បញ្ជាទាំងឡាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឱ្យប្រព្រឹត្តបទល្មើសទាំងនេះ គឺជាបញ្ជាខុសច្បាប់"[38]។ សូម្បីតែករណីដែល អោ អាន បានពឹងផ្អែកដើម្បីគាំទ្រដល់អំណះអំណាងរបស់គាត់ក៏មានបញ្ជាក់ចំណុចនេះដែរ[39]។ មន្ត្រី Bosnian Serb ម្នាក់ឈ្មោះ Drago Nikolić ធ្លាប់បានតវ៉ាថា ការធ្វើតាមបញ្ជាដើម្បីអនុវត្តការសម្លាប់រង្គាល នៅ Srebrenica គឺដោយសារ "ការព្យាយាមទាំងងងឹតងងុលរបស់គាត់ចំពោះសេវាសន្តិសុខ" មានន័យថា គាត់គ្មានចេតនាចាំបាច់ក្នុងការប្រព្រឹត្តិការធ្វើទុក្ខបុកម្នេញ និងចេតនារួម នៅក្នុងការ

---

[37] *សហរដ្ឋ ទល់នឹង Ohlendorf នឹងគូកន.*, មតិ និងសាលក្រម, ចុះថ្ងៃទី៨-៩ ខែមេសា ឆ្នាំ១៩៤៨ ("សាលក្រម *Einsatzgruppen*"), សវនាការលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធានូរ៉ាំប៊ឺក នៅក្រោមច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០, ភាគ IV, ទំព័រ ៤៧០-៤៧១ ["ការគោរពរបស់ទាហានម្នាក់ មិនមែនជាការគោរពរបស់គ្រឿងយន្តស្វ័យប្រវត្តិកម្មទេ។ ទាហានគឺជាភ្នាក់ងារដែលមានហេតុផល។ គាត់មិនឆ្លើយតបទេ ហើយក៏មិនសង្ឃឹមថានឹងឆ្លើយតប ដូចផ្នែកណាមួយនៃគ្រឿងម៉ាស៊ីននោះដែរ។ មានជំនឿខុសមួយដែលគេតែងតែប្រើយ៉ាងទូលំទូលាយនោះគឺថា ទាហានតែងតែគោរពតាមអ្វីៗគ្រប់យ៉ាងដែលមន្ត្រីថ្នាក់លើរបស់ខ្លួនបញ្ជាគាត់ឱ្យធ្វើអ្វីមួយ។ [...] អ្នកក្រោមបង្គាប់មានកាតព្វកិច្ចគោរពតែបញ្ជាធម្មានុរូបរបស់ថ្នាក់លើរបស់ខ្លួនប៉ុណ្ណោះ ហើយបើសិនជាគាត់ទទួលយកបញ្ជាឧក្រិដ្ឋ និងអនុវត្តវា ជាមួយនឹងគំនិតព្យាបាទរបស់ខ្លួនឯងផ្ទាល់ គាត់មិនអាចយកបញ្ជារបស់ថ្នាក់លើធ្វើជាលេសដើម្បីសម្រាលដល់បទល្មើសរបស់ខ្លួនឡើយ។ បើសិនជាប្រភេទនៃសកម្មភាពដែលបានបញ្ជាជាក់ស្តែងវាហួសពីវិសាលភាពនៃសិទ្ធិអំណាចរបស់ថ្នាក់លើ នោះអ្នកក្រោមបង្គាប់មិនអាចយកភាពមិនដឹងមិនឮធ្វើជាលេសចំពោះឧក្រិដ្ឋភាពនៃបញ្ជានោះឡើយ"]។*សហរដ្ឋ ទល់នឹង Milch*, សាលក្រម, ចុះថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ១៩៤៧ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ច្បាប់នៃស្តីពីសវនាការឧក្រិដ្ឋជនសង្គ្រាម, ភាគ VII, ទំព័រ ៤០-៤២, ៦៥ [តុលាការយោធាសហរដ្ឋ បានទាត់ចោលសំណើរសុំអភ័យទោសដែលយកមូលហេតុបញ្ជាថ្នាក់លើធ្វើជាលេសដើម្បីសម្រាលទោស ដោយបានផ្តល់ទឡ្ហីករណ៍ថា បញ្ជាទាក់ទងនឹងការធ្វើសង្គ្រាមឈ្លានពាន មានការពាក់ព័ន្ធនឹងការប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ និងភេរវកម្មដែលចុងចោទ *ត្រូវតែបានដឹងថា* វាជាអំពើអនុត្យានុកូល]។ *សហរដ្ឋ និងគូកន ទល់នឹង Göring និងគូកន.*, សាលក្រម, ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦, សវនាការឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ, ភាគ I, ទំព័រ ២៩០-២៩១ ["បញ្ជាថ្នាក់លើ ទោះបីសម្រាប់ទាហានក៏ដោយ មិនអាចត្រូវបានពិចារណាសម្រាប់ការសម្រាលដល់ឧក្រិដ្ឋកម្មដ៏សែនរន្ធត់ និងដែលមានលក្ខណៈទូលំទូលាយដែលបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ ដ៏គ្មានត្រាប្រណី និងគ្មានលេស ឬយុត្តិកម្មផ្នែកយោធានោះឡើយ""]។

[38] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម ឌុចរបស់សាលាដំបូង"), កថាខណ្ឌ ៥៥២។

[39] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ២៨។

អនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមនៅក្នុងការធ្វើមនុស្សឃាត[40]ឡើយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានច្រានចោលអំណះអំណាងរបស់គាត់ ដោយធ្វើការសម្រេចយ៉ាងដូច្នេះថា៖

> អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលយកផងដែរនូវភ័ស្តុតាងដែលថា Nikolić បានបូជាដើម្បីសេវាសន្តិសុខ។ ដូចបានកត់សំគាល់ដោយអង្គជំនុំជម្រះសាលាដំបូងដែរ កត្តាដូច្នេះមិនយកជាយុត្តិកម្ម ឬជាលេសក្នុងការអនុវត្តបញ្ជាខុសច្បាប់យ៉ាងជាក់ស្តែងដូច្នេះឡើយ។ ទាក់ទងចំណុចនេះ កត្តាបែបនេះមិនពាក់ព័ន្ធនឹងការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលទេ[41]។

17. ដោយសារការអនុវត្តដ៏តឹងរ៉ឹងចំពោះបញ្ជាថ្នាក់លើរបស់ អោ អាន បានធ្វើឱ្យមនុស្សរាប់ម៉ឺននាក់ដែលស្ថិតក្រោមការត្រួតត្រារបស់គាត់ក្នុងតំបន់៥១ ត្រូវបានធ្វើឱ្យទៅជាទាសករ[42] ដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌដ៏អមនុស្សធម៌[43] ទទួលរងទារុណកម្ម[44] បង្ខំឱ្យរៀបការនិងរួមភេទ[45] ធ្វើទុក្ខបុក

---

[40] *វុយ្ឡាឌូជា ទល់នឹង Popović នឹងគូកន.,* IT-05-88-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥, (សាលដីការឿងក្តី *Popović*"), កថាខណ្ឌ ៧២៣, ១០២៧-១០២៨។

[41] សាលដីការឿង *Popović*, កថាខណ្ឌ ៥១៥។

[42] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ២៧, ៤០។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ"), កថាខណ្ឌ ៧៤-៧៥, ២៨៧-២៩១, ៦៥៤, ៦៥៦, ៦៥៨, ៦៦៣។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កំណត់សំគាល់ជើងទំព័រ ១៣៩(iii)។

[43] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ២០, ២២-២៣, ២៥-២៦។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១២៧, ១៥៦, ២១៤-២១៥, ២៥៨-២៦១, ៣១៦-៣១៩។

[44] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ២០, ២២-២៣, ២៥-២៦, ៧១(គ), ១០៩។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១២៨, ១៥៧, ២៦២-២៦៣, ៣២៣-៣២៦។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៦៥-៦៦។

[45] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ២៩, ១០៩។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧៣(xxxi-xxxv), ៤៤១-៤៦១។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៤៥, ៥៥, ១០២-១០៣, កំណត់សំគាល់ជើងទំព័រ ៦៨(៩), ៧៧, ១៣៩(xxii-xxiv)។

ម្មេញ[46] និង/ឬ ចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង និងសម្លាប់តាមទំនើងចិត្ត[47]។ លើសពីការអនុវត្តបញ្ជារបស់ អោ អាន នៅពេលគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ បញ្ជាទាំងនេះជាក់ស្តែងគឺសុទ្ធតែខុសច្បាប់ និងជាការពិតដែលថា ការធ្វើតាមបញ្ជាទាំងនេះនាំឲ្យគាត់ទទួលបានទម្ងន់តិចតួចក្នុងពេលធ្វើការវាយតម្លៃលើការទទួលខុសត្រូវជាបុគ្គលរបស់គាត់។

18. ចម្លើយតបរបស់ អោ អាន បង្ហាញថាគាត់ជាជនរងគ្រោះម្នាក់នៃការបង្ខិតបង្ខំ និងការគាបសង្កត់ ដោយអះអាងថា ស.ព.អ បានប្រមាថដល់ចារីខ្មែរក្រហមជាសហជីវិន/សហជីវិនីរបស់គាត់ជាច្រើនពាន់នាក់ផ្សេងទៀត ដែលពួកគេត្រូវបានបង្ខំឲ្យប្រព្រឹត្តអំពើព្រហ្មទណ្ឌដូចគាត់ដែរ ដោយសារតែការភ័យខ្លាចចំពោះជីវិតរបស់ខ្លួន[48]។ ស.ព.អ មិនសុំទោសចំពោះការផ្តោលទោសនូវសកម្មភាពរបស់ជនទាំងឡាយដែលបានធ្វើឲ្យក្លាយជាទាសករ និងបានសម្លាប់ជនរួមឈាមខ្លួនឯងឡើយ។ អោ អាន មិនមែនជាជងរងគ្រោះទេ។ ផ្ទុយទៅវិញ គាត់បានឡើងឋានៈនិងតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការរួមចំណែកយ៉ាងសកម្ម គ្មានត្រាប្រណី និងដ៏សំខាន់បំផុតដល់ការអនុវត្តគោលនយោបាយនានារបស់ បកក។

19. ឌុច ធ្លាប់ទាមទារដូចគ្នានេះដែរនៅក្នុងសវនាការរបស់គាត់ថា អ្វីៗដែលគាត់បានធ្វើ គឺដើម្បីអនុវត្តបញ្ជាឲ្យធ្វើទារុណកម្ម និងប្រតិបត្តិតាមបញ្ជាដែលគាត់បានទទួល ដោយសារមានការបង្ខិតបង្ខំនៃ

---

[46] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ២១-២២, ២៥, ២៨, ៧០, ៨១, ៩៥, ១០៩។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៣៥, ១៦៤, ២២៣-២២៦, ២៣៩-២៤០, ២៦៩-២៧០, ៣៤១-៣៥៧, ៣៧៨-៣៨៧។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ២៦, ៧៣-៧៦, ១០៦-១១១, កំណត់សំគាល់ជើងទំព័រ ៦៨(៧)។

[47] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ១៨-២៦, ២៨, ៤០, ៦៩-៧១, ៨១, ៩៥, ១០៩។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧-៣៥, ១២២-១២៦, ១២៩-១៣៤, ១៤៩-១៥៥, ១៥៨-១៦៣, ១៧៧-១៩២, ២០៤-២១៣, ២១៦-២២២, ២៣២-២៣៨, ២៥៤-២៥៧, ២៦៤-២៦៨, ២៩៤-២៩៥, ៣០៩-៣១៥, ៣២៧-៣៤០, ៣៥០-៣៥៧, ៣៩៧-៤១២។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៥៦, ៦០, ៦៤-៦៦, ៦៩-៧០, ៧៤-៧៦, ១០៦-១១១, កំណត់សំគាល់ជើងទំព័រ ៦៨(៤), ៦៨(៦-៧), ៩១។

[48] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១៧។

របបដែលគាត់កំពុងតែបំរើ[49]។ អង្គជំនុំជម្រះបានច្រានចោលការអះអាងរបស់គាត់នេះ ដោយបានសម្រេចថា “[...]គេមិនអាចអះអាងថាមានការគាបសង្កត់នោះទេ នៅពេលដែលការគំរាមកំហែងនោះកើតចេញពីការអនុវត្តគោលនយោបាយដែលធ្វើឲ្យមានការភ័យរន្ធត់ ដែល[ជនជាប់ចោទ]ខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត”[50]។ ដូចគ្នានឹង ឌុច ដែលបានអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំងនៅស-២១ដែរ អោ អាន បានអនុវត្តគោលនយោបាយដូចគ្នា (និងច្រើនជាងនេះ) នៅទូទាំងតំបន់៤១ និងហួសពីតំបន់នេះទៅទៀត។ ការប៉ុនប៉ងរបស់គាត់នៅពេលនេះដើម្បីបង្ហាញខ្លួនឯងឲ្យគេឃើញថា ជាជនរងគ្រោះនៃគោលនយោបាយដូចគ្នាបេះបិទទៅនឹងគោលនយោបាយនានាដែលគាត់បានជួយពន្លឿននោះ មិនទទួលបានកត្តិយសដូច្នេះទេ។

---

[49] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **F1/4.1** កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ, ប្រតិចារិត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១, 16.29.05-16.33.45 [ឌុច: សិទ្ធិសម្រេចកម្ទេច ជាគោលការណ៍ដែលខ្ញុំគោរពយ៉ាងម៉ឺងម៉ាត់ដាច់ខាត។ [...] ខ្ញុំសូម[រាយការណ៍ជូនតុលាការថា] អ្នកដែលល្មើសនឹងសិទ្ធិអំណាចសម្រេចកម្ទេចនេះ ពិតជាត្រូវបក្សកម្ទេចចៀសមិនរួច ដូចជា កុយ ធួន និង អ៊ិន លន ហៅ ណាត ជាដើម។ ខ្ញុំជឿថា ខ្ញុំដែលរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ គឺដោយសារខ្ញុំគោរពគោលការណ៍នេះ[...] យ៉ាងម៉ឺងម៉ាត់ [...] គោលការណ៍របស់បក្ស ភារកិច្ចរបស់បក្សអីដែលបក្សប្រគល់ឲ្យត្រូវតែធ្វើ។ អ្នកឯងមិនធ្វើមិនបានៗ [គឺនឹងត្រូវកម្ទេច]។ ចំណែកការងារប្រចាំថ្ងៃនៅស-២១វិញ ខ្ញុំពិតជាត្រូវបានជម្រុញ ឬយើងហៅថា គាបសង្កត់ក៏បាន។ គឺគាបសង្កត់ជាប់ជាប្រចាំរបស់មេ”], 16.40.45-16.42.00 [ឌុច: ខ្មែរក្រហមគ្រប់រូបទទួលស្គាល់ខាងផ្លូវចិត្តថា ទោះបីជាយើងជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន ហ៊ានលះបង់អ្វីគ្រប់យ៉ាងរហូតដល់ត្រៀមលះបង់ជីវិតក៏ដោយ ក៏មាគ៌ាបក្សយើង វាជាមាគ៌ាឧក្រិដ្ឋ ព្រោះបក្សយើងអនុវត្តផ្តាច់ការវណ្ណៈអធន ឯងឹតឯងុលជ្រុលហួសហេតុពេក ប្រើគ្រប់មធ្យោបាយដើម្បីគាបសង្កត់យើងឲ្យអនុវត្តមាគ៌ាគេ។ បើយើងមិនអនុវត្ត ឬអនុវត្តដោយខ្ជីខ្ជា យើងពិតជាត្រូវគេកាត់ក្បាលមិនខាន [យើងពិតជារងគ្រោះថ្នាក់ដល់ជីវិត]។ ក្រោមពាក្យស្លោកថា [...] “ប្រឆាំងបក្ស ប្រឆាំងមាគ៌ា”]។

[50] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច របស់សាលាដំបូង, កថាខណ្ឌ ៥៥៧។ *សូមមើលផងដែរ* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ៣៩ *លើកយោង* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច របស់សាលាដំបូង, កថាខណ្ឌ ៦០៧។ *សូមមើលបន្ថែម* សាលក្រម *Einsatzgruppen*, ទំព័រ ៤៨០ [“អ្នកធ្វើអាចមិនទទួលបានឈ្មោះថា ជាជនស្លូតត្រង់ពីអំពើព្រហ្មទណ្ឌដែលបានបញ្ជាដោយថ្នាក់លើរបស់គាត់ឡើយ បើសិនជាគាត់មានភាពស្របគ្នាជាមួយនឹងគោលការណ៍ និងចេតនារបស់ថ្នាក់លើរូបនោះ។ នៅពេលដែលចេតនារបស់អ្នកធ្វើបន្សុីគ្នាជាមួយនឹងចេតនាថ្នាក់លើនៅក្នុងការអនុវត្តសកម្មភាពខុសច្បាប់ អ្នកធ្វើមិនអាចស្នើសុំសម្រាលទោស/អភ័យទោសដោយលើកយកការគាបសង្កត់នៅក្រោមបញ្ជារបស់ថ្នាក់លើធ្វើជាហេតុផលបានឡើយ”]។ មតិជំទាស់របស់ Cassese ក្នុងរឿងក្តី *Erdemović*, កថាខណ្ឌ ១៦-១៧ [“យោងតាមច្បាប់យុត្តិសាស្ត្រស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ ការគាបសង្កត់ ឬភាពចាំបាច់ មិនអាចយកជាលេសដើម្បីគេចចេញពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌបានឡើយ ចំពោះជនដែលមានបំណងចង់ប្រើប្រាស់ជាប្រយោជន៍នៃការការពារក្តីរបស់ខ្លួន បើសិនជាជននោះបានជ្រើសរើសធ្វើជាសមាជិកនៃអង្គភាព អង្គការ ឬក្រុមណាមួយដោយសេរីនិងដោយបានដឹងជាមុន ដោយមានចេតនាអនុវត្តជាស្ថាប័នទៅលើសកម្មភាពនានាដែលផ្ទុយពីច្បាប់មនុស្សធម៌អន្តរជាតិ”]។

20. តាមពិត អោ អាន បានចូលរួមជាមួយខ្មែរក្រហមដោយស្ម័គ្រចិត្តនៅក្រោយរដ្ឋប្រហារខែមីនា ឆ្នាំ ១៩៧០ បានចូលបំរើការងារធ្វើជាមេបញ្ជាការយោធា និងសមាជិកជិកគណៈស្រុក និងគណៈតំបន់ជាច្រើននៅក្រៅទីក្រុងភ្នំពេញ និងនៅភូមិភាគនិរតីក្នុងរយៈពេលប្រាំពីរឆ្នាំបន្ទាប់[51]។ បន្ទាប់មក គាត់ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល ហើយបានតម្លើងឋានៈជាលេខាតំបន់៤១ និងជាអនុលេខាភូមិភាគកណ្តាល[52]។ ក្នុងតួនាទីទាំងនោះ អោ អាន បានជួយលើកកម្ពស់គោលនយោបាយរបស់ បកក។ គាត់បានបញ្ជាឲ្យអ្នកក្រោមបង្គាប់របស់គាត់ប្រព្រឹត្តបទឧក្រិដ្ឋ បានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនោះដោយផ្ទាល់ និងបានតាមដានសកម្មភាពរបស់អ្នកក្រោមបង្គាប់របស់គាត់ដើម្បីធានាថាពួកគេពិតជាបានអនុវត្តបញ្ជាទាំងនោះ[53]។ ក្នុងរយៈពេលដ៏យូរ វិសាលភាព និងសារសំខាន់នៃការរួមចំណែករបស់ អោ អាន ចំពោះផែនការឧក្រិដ្ឋកម្មរួមនៅក្នុងតំបន់៤១ បង្ហាញឲ្យឃើញពីការចូលរួមប្រព្រឹត្តយ៉ាងសកម្ម និងដោយចេតនារបស់គាត់[54]។

---

[51] *សូមមើល ជាឧទាហរណ៍* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦-៨។

[52] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ១៨។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៩-១៥។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៥៥-៥៩, ៨០-៨៣។

[53] *សូមមើល ជាឧទាហរណ៍* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ១៨-៣១, ៤០, ៦៨-៧១, ៨១-៨៦, ៩៥, ១០៩។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧, ១៩-២១, ២៣, ២៧-២៨, ៣១-៣៥, ៤១, ៤៣, ៥១-៥៣, ៥៦-៦២, ៧៣-៧៥, ១១៩-១២១, ១៤៨, ១៥០-១៥១, ១៦០-១៦១, ១៧០-១៧២, ១៧៧, ១៧៩, ១៨៨, ២០០-២០៤, ២២២, ២៣១, ២៣៧, ២៥១, ២៧៤-២៧៥, ២៧៩-២៨១, ២៩១, ៣០៦-៣០៨, ៣៤៥, ៣៤៧-៣៤៩, ៣៥១, ៣៩៤, ៣៩៨-៤០១, ៤០៦, ៤៤១-៤៤២, ៤៤៤, ៤៤៧, ៤៤៩-៤៥០, ៤៥៥-៤៥៦, ៦៧៥-៦៧៩។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៥៥-៥៦, ៦៦-៧០, ៧៤-៧៦, ៨៥-៨៧, ១០២, ១០៦-១០៧, ១១០ កំណត់សំគាល់ជើងទំព័រ ៦៨(៨)។

[54] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កថាខណ្ឌ ១៧។ ការជំទាស់តវ៉ារបស់ អោ អាន ថាការទាមទាររបស់ ស.ព.អ គ្មានមូលដ្ឋាននិងពឹងផ្អែកលើភស្តុតាងចចាមអារ៉ាម ឬជាភស្តុតាងមិនគួរឲ្យទុកចិត្តបាននិងជឿជាក់បាននោះ គឺគ្មានអង្គសេចក្តីឡើយ។ អោ អាន ញែកភស្តុតាងចេញ និងធ្វើមិនដឹងមិនឮចំពោះភាពស៊ីសង្វាក់គ្នានៃភស្តុតាងទាំងមូល ព្រមទាំងមិនគោរពចំពោះការពិតដែលថា ភស្តុតាងចចាមអារ៉ាមត្រូវបានទទួលយកនៅ អ.វ.ត.ក។ ស.ព.អ បានលើកអំពីអភិក្រមដែលមានកំហុសរបស់អោ អាន ចំពោះភស្តុតាងនៅកន្លែងផ្សេងទៀតនិងធ្វើការបង្រួបបង្រួមភស្តុតាងទាំងនោះតាមរយៈសេចក្តីយោង *សូមមើល ជាឧទាហរណ៍* ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៤៨, ៥២-៥៣)។ នៅក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់ជាក់លាក់របស់ អោ អាន, អំណះអំណាងរបស់ អោ អាន ដែលថា ពេញ វ៉ា មិនស្របគ្នានឹងអ្វីដែល សាត ភាព និយាយនោះ គឺដោយសារកំណត់ហេតុ

21. លើសពីនេះទៀត អំពើប្រព្រឹត្តរបស់ អោ អាន នៅក្រោយការដួលរលំនៃរបបនេះ បិទបាំងការប៉ុនប៉ងបច្ចុប្បន្នរបស់គាត់ដើម្បីបង្ហាញខ្លួនគាត់ថាជាជនរងគ្រោះស្មោក់ស្មើម្នាក់។ ជាជាងការព្យាយាមគេចចេញពី "អ្នកចាប់ចង" របស់គាត់ ឬ ចូលរួមនៅក្នុងកងកម្លាំងណាមួយដែលប្រឆាំងទៅនឹង ប.ក.ក អោ អាន បានបន្តសម្របខ្លួនគាត់ជាមួយនឹង ប៉ុល ពត និង ថ្នាក់ដឹកនាំរបស់ ប.ក.ក ដែលកំពុងរស់នៅក្នុងតំបន់កាន់កាប់ដោយខ្មែរក្រហម[55]។ នៅឆ្នាំ២០១១ នៅពេលសម្ភាសអំពីបទពិសោធន៍របស់គាត់ អោ អាន បានប្រាប់ទៅ DC-Cam ថា គាត់បានពេញចិត្ត ពេញថ្លើម

---

របស់ ពេញ វ៉ា គឺជា "ភ័ស្តុតាងចចាមអារ៉ាមពីបុគ្គលម្នាក់ដែលស្គាល់អត្តសញ្ញាណខ្លះដែលបានទទួលមរណៈភាពទៅហើយ" មិនរឹងមាំអាចតទល់នឹងការពិនិត្យពិច័យបានឡើយ (*សូមមើល* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កំណត់សំគាល់ជើងទំព័រ៣៤។ ស.ព.អ បានយោង សាត ភាព និង ពេញ វ៉ា ចំពោះភ័ស្តុតាងរបស់ពួកគេទាក់ទងនឹងភាសាឃោរឃៅដែល អោ អាន បានប្រើនៅក្នុងសុន្ទរកថារបស់គាត់ស្ដីអំពីខ្មាំង (*សូមមើល* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ,កថាខណ្ឌ ៤០)។ ផ្នែកចចាមអារ៉ាមនៃចម្លើយដែលបានយោងរបស់ ពេញ វ៉ា មិនពាក់ព័ន្ធនឹងកិច្ចប្រជុំដែល អោ អាន បានប្រើពាក្យឃោរឃៅនោះទេប៉ុន្តែវាទាក់ទងនឹងមនុស្សដែលគេបានចាប់ដាក់ឡានទៅត្រង់ផ្សារព្រៃទទឹងដែលគេបានដឹកយកទៅភ្នំប្រុស។ កំណត់ហេតុរបស់ សាត ភាព និង ពេញ វ៉ា គឺស៊ីសង្វាក់គ្នាទាក់ទងនឹងគោលបំណងដែលពួកគេបាននិយាយសំដៅ (*សូមមើល* ឯកសារ **D219/504** កំណត់ហេតុស្ដាប់ចម្លើយ សាត ភាព,ឆ:២៤-២៥។ ឯកសារ**D219/226** កំណត់ហេតុស្ដាប់ចម្លើយ សាត ភាព,ឆ:៦។ ស្រដៀងគ្នានេះដែរ ស.ព.អ បានយោងកំណត់ហេតុស្ដាប់ចម្លើយ សូ សារ៉េន ដែលនិយាយថា គាត់បានឃើញ អោ អាន បញ្ជាឱ្យទាហានសម្លាប់ និងវះពោះស្ត្រីមានផ្ទៃពោះម្នាក់ ដែលគាត់តែងតែមកសួរនាំនៅមន្ទីរតំបន់អំពីប្ដីរបស់គាត់ដែលគេបានចាប់ខ្លួនយកទៅ (*សូម មើល* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ៤០)។ អោ អាន ជាថ្មីម្ដងទៀតបានយល់ច្រឡំពីអ្វីដែលជាផ្នែកនៃភ័ស្តុតាងចចាមអារ៉ាមរបស់ សូ សារ៉េន។ សូ សារ៉េន បាននិយាយចំៗថា "ខ្ញុំធ្លាប់ឃើញព្រឹត្តិការណ៍មួយ" នៅពេលរៀបរាប់អំពីបញ្ជាដែលបានផ្ដល់ដោយ អោ អាន និងពាក្យចចាមអារ៉ាមទាក់ទងនឹងអ្នកដែលប្រាប់គាត់ថា ស្ត្រីនោះត្រូវបានសម្លាប់នៅវាលស្រែខាងក្រោយមន្ទីរតំបន់: "ខ្ញុំដឹងថា តែយកទៅគឺសម្លាប់ហើយ"។ (*សូមមើល* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កំណត់សំគាល់ជើងទំព័រ ៣៤។ ឯកសារ **D219/837** កំណត់ហេតុស្ដាប់ចម្លើយ សូ សារ៉េន, ឆ:៧៥-៧៧)។ ជាចុងក្រោយ ស.ព.អ បានយោងភ័ស្តុតាងដើម្បីបង្ហាញឱ្យឃើញថា ការសម្លាប់នៅតំបន់៤១ នៅតែបន្តរហូតដល់ចុងរបបទោះបីជាមានសារាចរណ៍ណែនាំរបស់បក្សក៏ដោយ។ អោ អាន យល់ស្របថា កំណត់ហេតុស្ដាប់ចម្លើយអាចមាននិយាយអំពីការសម្លាប់ដែលចេះតែបន្ត ប៉ុន្តែគាត់តវ៉ាថា មិនមានអ្វីដែលនិយាយថា អោ អាន បានបញ្ជា ឬការពាក់ព័ន្ធណាមួយទៅនឹងការសម្លាប់ទាំងនោះទេ។ ស.ព.អ កត់សំគាល់ថា ភ័ស្តុតាងដែលបានយោង និងប្រយោគជាបន្តបន្ទាប់ដែលនិយាយអំពីសេចក្ដីណែនាំរបស់ អោ អាន ឱ្យប្រមូលបញ្ជីឈ្មោះចាមឱ្យបានត្រឹមត្រូវនោះ គាំទ្រដល់ការសន្និដ្ឋានថា អោ អាន មិនដែលបញ្ជាឱ្យអ្នកក្រោមបង្គាប់របស់គាត់ឱ្យអនុវត្តតាមសារាចរណ៍នោះទេ (*សូមមើល* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ, កថាខណ្ឌ ៤០។ ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន, កំណត់សំគាល់ជើងទំព័រ ៣៤)។

[55] *សូមមើល ឧ.* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤១, ១១០។

ជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ[56]។ ទាំងអស់នេះមិនមែនជាអំពើ ឬ ជាពាក្យពេចន៍របស់ជនរងគ្រោះនោះទេ។

22. ទាក់ទងទៅនឹងភាពពេញលេញនៃភ័ស្តុតាង វាច្បាស់លាស់ណាស់ដែលថា ស.ច.ស.ជ បានផ្តល់ការថ្លឹងថ្លែងមិនសមស្របលើអង្គហេតុដែលថា អោ អាន បានធ្វើតាមបញ្ជារបស់ កែ ពក និងទៅលើសេចក្តីថ្លែងតែមួយគត់ដែលថា បើសិនជា អោ អាន មិនគោរពតាមបញ្ជាទេនោះ គាត់នឹងត្រូវបានគេសម្លាប់ចោល[57]។ ភ័ស្តុតាងនេះស្ថិតនៅឆ្ងាយពីការបង្ហាញឲ្យឃើញថា អោ អាន មិនមានជម្រើសក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់នោះឡើយ ថាគាត់ត្រូវបានគំរាមកំហែងដោយផ្ទាល់ ឬថាគាត់បានព្យាយាមផ្តាច់ខ្លួនគាត់ចេញពីការប្រព្រឹត្តអំពើ ឧក្រិដ្ឋទាំងនេះ[58]។ នៅពេលដែល អ.ជ.ត.ក ពិនិត្យពីការសម្រេចទោស ឌុច អង្គជំនុំជម្រះនេះបានសម្រេចថា ស្ថានសម្រាលទោសដោយមូលហេតុ "បរិយាកាសគាបសង្កត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" គឺមានកម្រិតអប្បរមា[59]។ បន្ថែមលើនេះ ដោយសារ ឌុច បានដឹងថាបញ្ជារបស់ថ្នាក់លើដែលគាត់បានទទួល គឺមិនស្របច្បាប់ និងមិន "មានការគំរាមកំហែង ដែលនាំទៅដល់ការបង្ខិតបង្ខំ" អង្គហេតុពិតដែលថា ឌុច បានទទួលបញ្ជាចំពោះឧក្រិដ្ឋកម្មរបស់គាត់ មិនមានអានុភាពស្ថានសម្រាលទោសទេ[60]។ ដូចដែលបានថ្លែង ដោយ ស.ច.ស នៅក្នុងសំណុំរឿង០០៤/១ "ការពិចារណាដែលត្រូវធ្វើឡើងលើបញ្ហាចោទអំពីយុត្តាធិការបុគ្គលពុំមែនខុសគ្នាទាំងស្រុងនឹងការពិចារណាសម្រាប់គោលបំណងដាក់ទោស"[61]។ ដោយសារកត្តានានានៃបញ្ជារបស់ថ្នាក់លើ ការគាបសង្កត់ និង ការបង្ខិតបង្ខំ ត្រូវបានផ្តល់នូវការថ្លឹងថ្លែងតិចតួច ឬក៏គ្មានសោះ

---

[56] *សូមមើល ឧ.* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤១, ១១០។

[57] *សូមមើល ឧ.* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣២-៤៦ (ជាពិសេស ជើងទំព័រ ៩៣-៩៥ *ដែលបានយោង* ការវិភាគរបស់ ស.ច.ស.ជ ក្នុងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩៦, ៥៣៣, ៥៥២-៥៥៣ *និងកថាខណ្ឌផ្សេងទៀត*)។

[58] សំណុំរឿង០០១-ឯកសារ **F28** សាលដីកាសំណុំរឿង *ឌុច* កថាខណ្ឌ ៣៦៤។

[59] សំណុំរឿង០០១-ឯកសារ **F28** សាលដីកាសំណុំរឿង *ឌុច* កថាខណ្ឌ ៣៦៣-៣៦៤។

[60] សំណុំរឿង០០១-ឯកសារ **F28** សាលដីកាសំណុំរឿង *ឌុច* កថាខណ្ឌ ៣៦៥ (*សូមមើលផងដែរ* កថាខណ្ឌ៣៧៣)។

[61] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ៣៨។

នៅក្នុងការសម្រេចទោស ឌុច នោះ ស.ច.ស.ជ គេមិនគួរណាបានផ្តល់ការថ្លឹងថ្លែងហួសហេតុ នៅក្នុងការវាយតម្លៃលើយុត្តាធិការ បុគ្គលរបស់គាត់ចំពោះ អោ អាន នោះទេ[62]។

## ២. ការអនុវត្តច្បាប់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ មិនស៊ីសង្វាក់គ្នា ទៅនឹងយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក

23. ការថ្លឹងថ្លែងច្រើនហួសហេតុដែលបានផ្តល់ឲ្យទៅលើបញ្ហារបស់ថ្នាក់លើ ការគាបសង្កត់ និង ការបង្ខិតង្ខំ គឺគ្រាន់តែជាឧទាហរណ៍មួយនៃវិធីដែលដីកាសម្រេចលើកលែងចោទប្រកាន់ បាន អនុវត្តច្បាប់នៅក្នុងវិធីមួយដែលមិនស៊ីគ្នាទាល់តែសោះទៅនឹងយុត្តិសាស្ត្រពីមុនៗ ដែលមាននៅក្នុង សំណុំរឿង ០០១[63]។ នៅក្នុងចម្លើយតបរបស់គាត់ អោ អាន បានព្យាយាមផ្តល់យុត្តិកម្មខ្លះៗ ចំពោះមូលហេតុដែល ឌុច ត្រូវបានសម្រេចថា "ទទួលខុសត្រូវខ្ពស់បំផុត" ហើយ អោ អាន មិនត្រូវបានសម្រេចថាដូច្នោះ។ គាត់អះអាងថា គាត់បានត្រួតត្រា "តែមួយផ្នែកតូចនៃរបបកម្ពុជា ប្រជាធិបតេយ្យ ចំណែក ឌុច គឺជាប្រធាន ស-២១ ដែលបានទទួលអ្នកទោសមកពីទូទាំង ប្រទេស"[64]។ ដូចដែលបានលើកឡើងនៅកន្លែងផ្សេងៗទៀតដែរ ទំហំនៃតំបន់ភូមិសាស្ត្រដែល គ្រប់គ្រងដោយបុគ្គលម្នាក់ មិនបានកំណត់ពីកម្រិតនៃការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋ កម្មនោះទេ បើវាពិតជាដូច្នោះមែននោះ មេបញ្ជាការម្នាក់នៃជំរុំកាប់សម្លាប់រង្គាល (ដូចជា ឌុច) អាចអះអាងថាមិនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដោយផ្អែក លើមូលដ្ឋានថា គាត់គ្រាន់តែត្រួតត្រាលើទឹកដីពីរបីពាន់ម៉ែត្រក្រឡាតែប៉ុណ្ណោះ[65]។ ផ្ទុយទៅវិញ វាគឺភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលរបស់

---

[62] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១៦។

[63] *សូមមើលបន្ថែមទៀត* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤៣-៤៦។

[64] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១៨។

[65] *សូមមើល* ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ កថាខណ្ឌ ៩០។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Lukić & Lukić*, IT-98-32/1-AR11*bis*.1, សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍របស់ Milan Lukić ទាក់ទងនឹងការណែនា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ២២។

ជនជាប់ចោទទៅវិញទេ ដែលជាប់ពាក់ព័ន្ធនោះ[66]។ ដូចដែល អោ អាន បានថ្លែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ គឺដូចគ្នាទៅនឹង "បទចោទព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ"[67]។

24. ទោះបីជាយ៉ាងដូច្នេះក៏ដោយ "យុត្តិកម្ម" របស់ អោ អាន ចំពោះមូលហេតុដែលថា ឌុច ត្រូវបានសន្និដ្ឋានថាជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ហើយគាត់មិនមែនទេនោះ មានកំហុសយ៉ាងច្រើន ។ ទោះបីជាតំបន់៤១ ជា "ផ្នែកតូចមួយនៃកម្ពុជាប្រជាធិបតេយ្យ" ក៏ដោយ ក៏វាមានទំហំធំជាងតំបន់ភូមិសាស្ត្រនៃ ស-២១ ឆ្ងាយណាស់។ អោ អាន ក៏បានគ្រប់គ្រងចំនួនប្រជាជនស៊ីវិលច្រើនជាងចំនួនអ្នកទោសដែលនៅក្រោមការគ្រប់គ្រងរបស់ ឌុច[68] គាត់បានបញ្ជាអ្នកនៅក្រោម

---

[66] *សូមមើល ឧ.* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង អ៊ឹម ចែម កថាខណ្ឌ៣២៩, ៣៣៥-៣៣៦ (ចៅក្រម Beauvallet និង Baik)។

[67] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្តីសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៨ ("បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ២២៧។

[68] ទោះបីជាវាមិនអាចកម្រិតចំនួនពិតប្រាកដនៃជនស៊ីវិលក្នុងតំបន់ ៤១ ក្នុងអំឡុងពេលដែល អោ អាន ជាលេខាតំបន់ក៏ដោយ សូម្បីតែ ដីកាសម្រេចលើកលែងចោទប្រកាន់ (ដែលមិនមានការសន្និដ្ឋានណាមួយទាក់ទងនឹងចំនួយ ក្រៅពីនិយាយថា ភ័ស្តុតាងឧកខានមិនបានបញ្ជាក់ថាជនរងគ្រោះ ៤០០.០០០ នាក់ បានស្លាប់នៅក្នុងភូមិភាគកណ្តាល - *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៩-៤២០) ផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់ដើម្បីបង្ហាញថា មានជនស៊ីវិលរាប់ពាន់នាក់ទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ អោ អាន ច្រើនជាងអ្នកទោសជាង ១២.២៧២នាក់ ដែល ឌុច ត្រូវបានសន្និដ្ឋានថាទទួលខុសត្រូវក្នុងសំណុំរឿង០០១។ <u>ជនស៊ីវិលនៃតំបន់ ៤១ ក្រោមការគ្រប់គ្រងរបស់ អោ អាន៖</u> ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧ ["មានមនុស្សចំនួនប្រមាណជា ១០.០០០ (មួយម៉ឺន) នាក់ បានស្លាប់នៅភ្នំប្រុស ផ្អែកលើមូលដ្ឋានឯកសាររបស់រដ្ឋាភិបាល"] ៣១១ ["បន្ទាប់រំដោះ បើតាមអ្នករដ្ឋការសម័យរដ្ឋកម្ពុជា ចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួនមានប្រហែលជា ៣០.០០០ (បីម៉ឺន) នាក់។"] ៣២២ ["តាមការប៉ាន់ស្មាន មានជនរងគ្រោះរាប់ពាន់នាក់ ឬ ប្រហែល ១០.០០០ (ម៉ឺន) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយ។"] ៣៣១ ["តាមការប៉ាន់ប្រមាណ មន្ទីរសន្តិសុខមិត្តសុបមានមនុស្សប្រហែល ២.០០០ (ពីរពាន់) នាក់ ត្រូវបានសម្លាប់ ឬស្លាប់ដោយសារជំងឺ។"] ៣៣៦ [ប៉ាន់ប្រមាណចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅគោកព្រីង មានចំនួនចាប់ពី ១០០០ ទៅ ២៥.០០០ នាក់] ៣៣៩ ["តាមការប៉ាន់ប្រមាណ ប្រជាជនប្រហែល ១.០០០ (មួយពាន់) នាក់ ឬ ១.៥០០ (មួយពាន់ប្រាំរយ) នាក់ ដែលត្រូវបានអង្គការកែនឲ្យធ្វើការនៅការដ្ឋានទំនប់អន្លង់ជ្រៃ។"] ៣៩៥ ["តាមសាក្សីមួយរូបបានប៉ាន់ប្រមាណថា មានចំនួនជនរងគ្រោះរាប់ពាន់ត្រូវបានសម្លាប់នៅទួលបេង។"]។ *កត់សម្គាល់*ថា ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានផ្តល់ការសន្និដ្ឋានណាមួយអំពីចំនួនជនរងគ្រោះដោយអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរឡើយ ហើយក៏មិនមានចំនួនសរុបនៃជនជាតិចាមដែលត្រូវបានសម្លាប់ដែរ។ <u>អ្នកទោសក្រោមការគ្រប់គ្រង</u>

បង្គាប់ក្នុងចំនួនច្រើនជាង[69] និងត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មជាច្រើនមុខ ជាពិសេស អោ អាន ត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ ខណៈដែល ឌុច វិញគឺមិនត្រូវបានចោទ

---

<u>របស់ ឌុច៖</u> សំណុំរឿង០០១-ឯកសារ **D99** ដីកាបញ្ជូនរឿងទៅជំនុំជម្រះកាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ("ដីកាដំណោះស្រាយ *ឌុច*") កថាខណ្ឌ៤៧, ១០៧, ១៤០ [ស.ច.ស បានផ្អែកការរកឃើញតួលេខលើ ឈ្មោះចំនួន ១២.៣៨០ នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានប្រមូលចងក្រង ដែលត្រូវបានកែតម្រូវជាបន្តបន្ទាប់ក្រោយមកទៀតមកត្រឹម ១២.២៧២ ឈ្មោះ ឬ ១២.២៧៣ នៅក្នុងអំឡុងពេលដំណាក់លាកជំនុំជម្រះ] សំណុំរឿង០០១-ឯកសារ **E188** សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង *ឌុច* កថាខណ្ឌ៣៤០, ៥៩៧, ៦០៣, ៦៣០។ សំណុំរឿង០០១-ឯកសារ **F28** សាលដីកាបណ្តឹងសាទុក្ខ *ឌុច* កថាខណ្ឌ ៧, ៣៧៦, ៣៨០, ៤១៦។

[69] ភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា អោ អាន បានបញ្ជាជាច្រើនទៅអ្នកក្រោមបង្គាប់លើសពី៤០ ទៅ៥០នាក់ ដូចបានបាន់ប្រមាណដោយដីកាសម្រេចលើកលែងចោទប្រកាន់ ព្រមទាំងច្រើនជាង២០០នាក់ នៃអ្នកក្រោមបង្គាប់ដែលបានប៉ាន់ស្មាននៅក្រោមការត្រួតត្រាដោយផ្ទាល់របស់ ឌុច នៅស-២១ ដោយសារដីកាសម្រេចលើកលែងចោទប្រកាន់ពិនិត្យទៅលើតែអ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ អោ អាន ដែលរស់នៅក្នុងមន្ទីរតំបន់៤១ ហើយដែលមិនបានពិចារណាទៅលើសមាជិកគណៈឃុំ និងស្រុកដែលបានរាយការណ៍ជូន អោ អាន ដោយផ្ទាល់ ឬដោយប្រយោល បុគ្គលិកនៃមន្ទីរសន្តិសុខនានានៅក្រោម ការត្រួតត្រារបស់គាត់នៅក្នុងតំបន់៤១ និងសមាជិកកងឈ្លប និងយោធាដែលជាអ្នកអនុវត្តបញ្ជាចាប់ខ្លួនមនុស្សរបស់គាត់ (*សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៤១, ៥០៧, ៥៤៥)។ បើយើងប្រើវិធីប៉ាន់ស្មានបែបអភិរក្សនិយមហួសហេតុដូចលម្អិតខាងក្រោម នោះភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា អោ អាន បានបញ្ជាអ្នកក្រោមបង្គាប់យ៉ាងហោចណាស់ក៏ ៣២៩នាក់ដែរ (គឺ៤០នាក់នៅមន្ទីរតំបន់៤១ + សមាជិកគណៈស្រុក ១៥នាក់ + សមាជិកគណៈឃុំ ១៩៥នាក់ + សមាជិក/បុគ្គលិកមន្ទីរសន្តិសុខ ៧៩នាក់)។ *សូមមើល ជាឧទាហរណ៍* **១. <u>អ្នកក្រោមបង្គាប់នៅមន្ទីរតំបន់៤១:</u>** ៤០ (*សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៤១, ៥០៧, ៥៤៥)។ **២. <u>អ្នកក្រោមបង្គាប់ថ្នាក់ស្រុកនៅក្នុងតំបន់៤១:</u>** ៥ស្រុក x ៣ សមាជិកឃុំក្នុងមួយស្រុក = ១៥ សមាជិកគណៈឃុំ (*សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៣៩; ឯកសារ **D1.3.15.1** កំណត់ហេតុនៃការវិភាគរបស់ ក្រេក អិតជិសុន, កថាខណ្ឌ៩ ["ស្រុកគ្រប់គ្រងដោយគណៈកម្មាធិការបក្សចំនួនបីនាក់"])។ **៣. <u>អ្នកក្រោមបង្គាប់ថ្នាក់ឃុំនៅក្នុងតំបន់៤១:</u>** ៥ស្រុក x ១៣ ឃុំក្នុងមួយស្រុក x ៣ សមាជិកគណៈឃុំ ក្នុងមួយឃុំ = ១៩៥ សមាជិកគណៈឃុំ។ *សូមកត់សំគាល់* ថាការគណនានេះ ប្រើស្រុកកំពង់សៀមជាឧទាហរណ៍ដែលមានឃុំដែលបានកំណត់អត្តសញ្ញាណហើយចំនួន១៤ ដែលឃុំនីមួយៗត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមួយដែលមានសមាជិកយ៉ាងហោចណាស់បីនាក់ (*សូមមើល* ឯកសារ **D1.3.15.1** កំណត់ហេតុនៃការ វិភាគរបស់ ក្រេក អិតជិសុន, កថាខណ្ឌ១០; (i) <u>ឃុំអំពិល:</u> ឯកសារ **D219/377** កំណត់ហេតុស្តាប់ចម្លើយ មន ម៉ុត, KH 01112252 [ស្រុកកំណើត], ឆ៖១។ **D219/543** កំណត់ហេតុស្តាប់ចម្លើយ ណាំ ម៉ុន, KH 01157510 [ស្រុកកំណើត]។ ឯកសារ **D219/711** កំណត់ ហេតុស្តាប់ចម្លើយ ឈន ប៉ិច, KH 01211239 [ស្រុកកំណើត]។ ឯកសារ **D3/4** កំណត់ហេតុស្តាប់ចម្លើយ ជិន ស៊ីណាល់, KH 00596356-57។ (ii) <u>ឃុំទ្រាន:</u> ឯកសារ **D219/484** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆៈ៣។ ឯកសារ **D117/38** កំណត់ហេតុស្តាប់ចម្លើយ គ្រួច គីម, ឆៈ៣-៤។ ឯកសារ **D219/707** កំណត់ហេតុស្តាប់ចម្លើយ ធឹម ធីម, KH 01211211 [ស្រុកកំណើត]។ ឯកសារ **D219/702.1.87** យូ វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, 14.20.45-14.23.05។ (iii) <u>ឃុំរអាង:</u> ឯកសារ **D219/138** កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់, ឆៈ១, ១៨។ ឯកសារ **D219/702.1.87** យូ

វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, 14.55.52-14.57.17, 15.00.23-15.03.27។ **D219/702.1.94** យូ វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦, 09.50.20-09.53.05។ (iv) <u>ឃុំក្រឡា:</u> ឯកសារ **D117/32** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល, ឆ:៩។ ឯកសារ **D117/71** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត, ឆ:៥៤។ ឯកសារ **D117/44** កំណត់ហេតុស្តាប់ចម្លើយ នៅ ហឿន, ឆ:២។ ឯកសារ **D219/136** កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់, ឆ:២។ ឯកសារ **D117/48** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តអង្គញដី និងទួលបេង, KH 01044564។ (v) <u>ឃុំវិហារធំ:</u> ឯកសារ **D219/83** កំណត់ហេតុស្តាប់ចម្លើយ សួន យឹម, ឆ:១។ ឯកសារ **D219/17** កំណត់ហេតុស្តាប់ចម្លើយ ពិន ដន, ឆ:៦។ ឯកសារ **D117/57** កំណត់ហេតុស្តាប់ចម្លើយ គាន ឡី, ឆ:៣។ ឯកសារ **D107/3** កំណត់ហេតុស្តាប់ចម្លើយ កាក់ ស្រឿន, KH 00784971-72។ ឯកសារ **D107/16** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, KH 00804732។ (vi) <u>ឃុំគគរ:</u> ឯកសារ **D219/706** កំណត់ហេតុស្តាប់ចម្លើយ យ៉ុប លី, KH 01211204, [ស្រុកកំណើត], ឆ:៣៤-៣៧។ ឯកសារ **D219/606** កំណត់ហេតុស្តាប់ចម្លើយ ជា ខេងថៃ, KH 01175098, [ស្រុកកំណើត]។ ឯកសារ **D219/709** កំណត់ហេតុស្តាប់ចម្លើយ តេះ រ៉ូន, KH 01211224, [ស្រុកកំណើត]។ ឯកសារ **D219/702.1.94** យូ វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦, 09.50.20-09.53.05។ (vii) <u>ឃុំកោះរកា:</u> ឯកសារ **D117/32** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល, KH 00964460-61, [ស្រុកកំណើត], ឆ:១-៤។ ឯកសារ **D219/59** កំណត់ហេតុស្តាប់ចម្លើយ មុំ ស្រៀង, KH 01037103, [ស្រុកកំណើត]។ ឯកសារ **<u>D219/702.1.85</u>** សយ ឌឿន, ប្រតិចារិក, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦, 10.14.24-10.16.52។ (viii) <u>ឃុំកៀនជ្រៃ:</u> ឯកសារ **D219/877** កំណត់ហេតុស្តាប់ចម្លើយ ឱម យ៉ាត, KH 01357603, [ស្រុកកំណើត]។ (ix) <u>ឃុំកោះសំរោង:</u> ឯកសារ **D117/3** កំណត់ហេតុស្តាប់ចម្លើយ ឆ្នូវ គឹមម៉ុល, KH 00872446, [ស្រុកកំណើត]។ ឯកសារ **D117/4** កំណត់ហេតុស្តាប់ចម្លើយ និន សុផល, KH 00872472, [ស្រុកកំណើត]។ (x) <u>ឃុំអូរស្វាយ:</u> ឯកសារ **D117/42** កំណត់ហេតុស្តាប់ចម្លើយ ខឹម នារី, ឆ:៥។ ឯកសារ **D117/37** កំណត់ហេតុស្តាប់ចម្លើយ ឡេង វ៉ា, ឆ:៥, ឆ:២២។ ឯកសារ **D219/800** កំណត់ហេតុស្តាប់ចម្លើយ ស្វ សារ៉េន, ឆ:២, ឆ:១៨។ (xi) <u>ឃុំស្រក់:</u> ឯកសារ **D117/38** កំណត់ហេតុស្តាប់ចម្លើយ គ្រួច គឹម, ឆ:៤។ ឯកសារ **<u>D219/702.1.87</u>** យូ វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, 14.20.45-14.23.05។ (xii) <u>ឃុំកោះមិត្ត:</u> ឯកសារ **<u>D219/702.1.87</u>** យូ វ៉ាន់, ប្រតិចារិក, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦, 14.20.45-14.24.23។ ឯកសារ **D117/32** កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល, KH 00964464 [ស្រុកកំណើត], ឆ:១៥។ ឯកសារ **D117/26** កំណត់ហេតុស្តាប់ចម្លើយ ពុត កុល, ឆ:១៤។ (xiii) <u>ឃុំហាន់ជ័យ:</u> ឯកសារ **D117/45** កំណត់ហេតុស្តាប់ចម្លើយ ធូ សុខខេង, KH 00987155-56, [ស្រុកកំណើត], ឆ:១។ ឯកសារ **D219/776.1.1** បទសម្ភាសន៍ DC-Cam ជាមួយ ស្វ សារ៉េន, EN 01309869។ **៤. <u>បានកំណត់អត្តសញ្ញាណថ្នាក់ក្រោមនៅមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៃតំបន់ ៤១ រួមទាំងសមាជិកយោធា/ឈ្លប៖</u>** (i) <u>គ (មិត្តសុប)៖</u> យុក ជុំយ + កែ (អនុ) + ទាហាន ៣០នាក់ ដែលបានត្រួតពិនិត្យមើលដំណើរការគុកប្រចាំថ្ងៃ = អ្នកក្រោមបង្គាប់ ៣២នាក់ (*សូមមើល* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៤-១៤៥)។ (ii) <u>វត្តតាមះ៖</u> ទាហានតំបន់ ១០-១២ នាក់ធ្វើជាអ្នកយាមក្នុងមួយក្រុម x ២ ក្រុម = អ្នកក្រោមបង្គាប់ ២០នាក់ (*សូមមើល* ឯកសារ **D219/504** កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.៤៩, ៥៦)។ (iii) <u>ទួលបេង និងវត្តអង្គញដី៖</u> នី + ចំនួនយោធាដែលមិនដឹងនៅមន្ទីរសន្តិសុខទួលបេង និងវត្តអង្គញដី = អ្នកក្រោមបង្គាប់ ១នាក់ (*សូមមើល*ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២០៣) (iv) <u>វត្តបាធាយ៖</u> ពិន ពៅ + លឹម (អនុ) + អ្នកយាម ៧នាក់ = អ្នកក្រោមបង្គាប់ ៩នាក់ (*សូមមើល* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២៤៧)។ (v) <u>វត្តអូរត្រកួន៖</u> ហ៊ីន + បុត/គួង (អនុ) + មុយ វ៉ាន់នី + សមាជិកដាវវែង ១៤នាក់

ប្រកាន់ដូច្នោះទេ[70]។ សេចក្តីអះអាងរបស់ អោ អាន ដែលថា ស-២១ *បានទទួល* អ្នកទោសពីក្នុងប្រទេសទាំងមូល[71] គឺគ្រាន់តែសង្កត់ន័យថា តួនាទីរបស់ ឌុច នៅក្នុងការផ្ទេរអ្នកទោសបែបនោះ គឺត្រូវបានកម្រិតយ៉ាងទូលំទូលាយត្រឹមតែការទទួលពួកគេប៉ុណ្ណោះ ចំណែកឯ អោ អាន គឺស្ថិតនៅក្នុងចំណុចកណ្តាលនៃបណ្តាញភ័ស្តុភារដ៏ធំមួយដែលបានសម្របសម្រួលការផ្ទេរប្រជាជនស៊ីវិល (រួមទាំង ប្រជាជនស៊ីវិលរាប់ពាន់នាក់ពីភូមិភាគបូព៌ាផង) ទៅកាន់ ឬ មកពី មន្ទីរសន្តិសុខនានានៅទូទាំងតំបន់៤១ ដែលរូបគាត់ និងអ្នកនៅក្រោមបង្គាប់របស់គាត់ បានកំណត់អត្តសញ្ញាណ ដើម្បីចាប់ខ្លួន និង/ឬ ដើម្បីសម្លាប់ចោល[72]។

= អ្នកក្រោមបង្គាប់ ១៧នាក់ (*សូមមើល* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣០១-៣០៤ ជើងទំព័រ ១០៥៩, ១០៦២-១០៦៤, ១០៦៦)។ ៣២ + ២០ + ១ + ៩ + ១៧ = ៧៩ នៃអ្នកក្រោមបង្គាប់នៅមន្ទីរសន្តិសុខដែលត្រូវបានកំណត់អត្តសញ្ញាណ។

[70] អោ អាន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនចាមនៅក្នុងភូមិភាគកណ្តាល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត អំពើសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ លក្ខខណ្ឌអមនុស្សធម៌នៃការឃុំឃាំង ការបំពារបំពានលើរាងកាយរបស់អ្នកទោស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងនយោបាយ និងអំពើមនុស្សឃាតគិតទុកជាមុន ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើឡើងនៅមន្ទីរសន្តិសុខវត្តតាមៈ មន្ទីរសន្តិសុខ គ (មិត្តសុប) ទីតាំងសម្លាប់មនុស្សភ្នំប្រុស មន្ទីរសន្តិសុខទួលបេង មន្ទីរសន្តិសុខវត្តអង្គញជី ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខវត្តបាធាយ ទំនប់អន្លង់ជ្រៃ មន្ទីរសន្តិសុខវត្តអូរត្រកួន និងស្រុកព្រៃឈរ និងស្រុកកំពង់សៀម ក្នុងករណីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (*សូមមើល* ឯកសារ **D242** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ EN 01096765-67។ ឯកសារ **D303** កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ EN 01213485-90។ ឯកសារ **D337** ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ EN 01363646)។ ឌុច ត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក៏ដូចជា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ឧក្រិដ្ឋកម្មទាំងនេះបានកើតមានឡើងនៅ មន្ទីរសន្តិសុខ ស-២១ និងទីតាំងសម្លាប់មនុស្សជើងឯក (*សូមមើល* សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយសំណុំរឿង *ឌុច* កថាខណ្ឌ១១២-១១៩ ផ្នែកសម្រេចសេចក្តី)។

[71] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១៨ (គូសបញ្ជាក់បន្ថែម)។

[72] *សូមមើល ឧ.* សំណុំរឿង០០១-ឯកសារ **D99** ដីកាដំណោះស្រាយសំណុំរឿង *ឌុច* កថាខណ្ឌ៣៨-៣៩, ៥១-៥៩។ ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៤៤, ៦៩-៧១។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៦៥-៧០, ៧២។ ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ១៩-៣៥, ៣៩-៤៦, ៥១-៥៣។

ចុងបញ្ចប់ អោ អាន បានប្រៀបធៀបការប្រាស្រ័យទាក់ទងជាធម្មតារបស់ ឌុច ជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ជាមួយនឹងកង្វះខាតផ្ទាល់របស់គាត់ចំពោះទំនាក់ទងបែបនោះ[73] ក៏ប៉ុន្តែចំណុចនេះ គ្រាន់តែ គូសបញ្ជាក់បង្ហាញថា អោ អាន ត្រូវទទួលបានការទុកចិត្តជាមួយនឹងឆន្ទានុសិទ្ធិច្រើនជាង ឌុច នៅក្នុងការកំណត់ពីជោគវាសនារបស់ជនទាំងឡាយ ដែលនៅក្រោមការគ្រប់គ្រងរបស់គាត់[74]។

## គ. ស.ច.ស.ជ បានបកស្រាយច្បាប់ដោយមិនត្រឹមត្រូវ នៅពេលដែលគាត់បានសន្និដ្ឋានថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់" ដែលនាំឲ្យគាត់អនុវត្តច្បាប់មិនបានត្រឹមត្រូវ

25. អោ អាន អះអាងថា ស.ព.អ "ជំទាស់តវ៉ាទាំងមិនត្រឹមត្រូវសោះថា សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា ឌុច គឺជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់""[75] សូម្បីតែអង្គហេតុពិតដែលថា អំណះអំណាងរបស់គាត់គឺផ្ទុយគ្នាទាំងស្រុងដោយពាក្យពេចន៍ចំៗ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់។ ទីមួយ ស.ច.ស.ជ បានថ្លែងថា "ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ <u>នឹងមិនរាលដាលដល់កម្មាភិបាលនៅថ្នាក់ក្រោមឡើយ ក្រៅពី ឌុច</u> ដែលមានឈ្មោះក្នុងគំនិតនៃអ្នកធ្វើច្បាប់"[76]។ បន្ទាប់មក នៅក្នុងផ្នែកដែលបានពិភាក្សាពីការចរចារស្ដីពីយុត្តាធិការបុគ្គល ដីកាសម្រេចលើកលែងចោទប្រកាន់ បានសន្និដ្ឋានថា៖

> ជាសរុប សកម្មភាព និងចេតនារបស់ភាគីកម្ពុជាទាំងមុន និងអំឡុងពេលនៃការចរចាបង្កើតច្បាប់ អ.វ.ត.ក បង្ហាញពីយុត្តាធិការបុគ្គលដ៏តូចចង្អៀត ដើម្បីរកយុត្តិធម៌ និង រក្សាបានសន្តិភាព។ មុខសញ្ញាទាំងនោះគឺមេដឹកនាំជាន់ខ្ពស់ និង <u>ឌុច ដែលជាបុគ្គលម្នាក់តែប៉ុណ្ណោះ ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត</u>។ ក្នុងដីកា ដំណោះស្រាយ០០៤/១ សហចៅក្រមស៊ើបអង្កេតអះអាងថា៖ ចៅក្រម

[73] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ១៨។

[74] ដូចដែលបានពិភាក្សាលម្អិតក្នុងឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៤៣-៤៤។

[75] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ២០-២១។

[76] **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៧៨ (គូសបញ្ជាក់បន្ថែម)។

នៅ អ.វ.ត.ក ត្រូវគោរពតាមសេចក្ដីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែង ច្បាប់[77]។

26. អោ អាន តវ៉ាថា ស.ច.ស.ជ មិនជឿជាក់ថាប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានកម្រិតត្រឹមតែ ខុច ពីព្រោះថាបើមិនដូច្នោះទេ ដីកាសម្រេចលើកលែងចោទប្រកាន់នឹងមិនមានការវិភាគដែលវាបានធ្វើឡើងដើម្បីបង្ហាញថា អោ អាន មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះទេ[78]។ ប៉ុន្តែពាក្យពេចន៍ដែលមានន័យច្បាស់លាស់របស់ដីកាសម្រេចលើកលែងចោទប្រកាន់ និងពាក្យរម្លឹកក្រោយមកទៀតដែលថា ចៅក្រម "ត្រូវគោរពតាមសេចក្ដីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់" បង្ហាញថា ស.ច.ស.ជ បានសន្និដ្ឋានរួចជាស្រេចហើយថា ប្រភេទជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" អាចត្រូវបានអនុវត្តចំពោះតែ ខុច ប៉ុណ្ណោះ។ ជាសង្ខេប ការវិភាគរបស់ដីកាសម្រេចលើកលែងចោទប្រកាន់គឺមានកំហុសជាមូលដ្ឋាន ដោយហេតុថាវាបានផ្អែកលើការបកស្រាយមិនត្រឹមត្រូវនូវច្បាប់គ្រប់គ្រង (កិច្ចព្រមព្រៀង អ.វ.ត.ក) ដែល ស.ច.ស.ជ ជឿជាក់ថាផ្ដល់អាណត្តិដល់គាត់ក្នុងការសន្និដ្ឋានថា អោ អាន មិនស្ថិតនៅក្នុងចំណោមជនទាំងឡាយណាដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដូច្នេះ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះឡើយ។

27. អោ អាន ខកខានមិនបានលើកឡើងពីកំហុសឆ្គងអង្គច្បាប់ដែលបានលើកឡើង និងដែលបានបញ្ជាក់នៅក្នុង ផ្នែក IV.គ. នៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ។ គាត់មើលរំលងភ័ស្តុតាងទាំងអស់ដែលបានដាក់បង្ហាញដែលថា ការចាត់ទុកថាប្រភេទដែល "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានកម្រិតត្រឹមតែ ខុច គឺផ្ទុយគ្នាដោយផ្ទាល់ទៅនឹងសេចក្ដីថ្លែងដែលបានធ្វើឡើងដោយអ្នកចរចាររបស់រាជរដ្ឋាភិបាលកម្ពុជានៅពេលដែលច្បាប់ អ.វ.ត.ក ត្រូវបានអនុម័ត គឺមិនស៊ីគ្នាជាមួយនឹងការយល់ឃើញយ៉ាងច្បាស់លាស់របស់អ្នកចចាររបស់ អ.ស.ប ផ្ទុយគ្នាទៅនឹងការសម្រេចដោយ អ.ជ.ត.ក និង ការសម្រេចរួមដោយ ស.ច.ស នៅក្នុងសំណុំរឿង អ.វ.ត.ក ដទៃទៀត មិនស៊ីគ្នាជាមួយនឹងភាសាធម្មតានៃច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង និង បំពានលើបទដ្ឋាន

[77] **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥៤២ (គូសបញ្ជាក់បន្ថែម)។

[78] **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២២-២៣។

និងការការពារសិទ្ធិមនុស្សអន្តរជាតិ[79]។ ចម្លើយតបរបស់ អោ អាន មិនបានប៉ុនប៉ងការពារអំណះអំណាងដែលថា ប្រភេទជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" មានគោលបំណងដាក់កម្រិតត្រឹមតែ ឧុច ពីព្រោះភ័ស្តុតាងបង្ហាញច្បាស់លាស់ថា នេះមិនមែនជាចេតនារបស់អ្នកទាំងឡាយដែលបានធ្វើតាក់តែងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក នោះឡើយ។

## ឃ. ដីកាសម្រេចលើកលែងចោទប្រកាន់បានវាយតម្លៃដោយមិនសមហេតុមិនសមផលនៅលើភ័ស្តុតាងសំខាន់ៗ ដែលជាកំហុសអង្គហេតុមួយដ៏សំខាន់ដើម្បីសម្រេចថា អោ អាន មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត"

28. ផ្ទុយទៅនឹងការអះអាងរបស់ អោ អាន បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ បានកំណត់កំហុសអង្គហេតុយ៉ាងត្រឹមត្រូវ ក្នុងរបៀបដែលដីកាសម្រេចលើកលែងចោទប្រកាន់ បានវាយតម្លៃភ័ស្តុតាង ជាពិសេសភ័ស្តុតាងរបស់ ប្រាក់ យុត ដែលឆ្លើយថា អោ អាន មានជាប់ពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្ម[80]។ ទោះបីជាភ័ស្តុតាងរបស់គាត់ត្រូវបានលើកឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ដើម្បីគាំទ្រដល់ការពិភាក្សាពីគោលនយោបាយនៅទូទាំងប្រទេស ដែលជាទូទៅគឺរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងទីកន្លែងនៃទីតាំងឧក្រិដ្ឋកម្ម[81] យ៉ាងណាក៏ដោយ ក៏ ស.ច.ស.ជ មិនអើពើលើភ័ស្តុតាងជាច្រើនរបស់ ប្រាក់ យុត ដែលឆ្លើយដាក់ អោ អាន ដោយផ្ទាល់[82]។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទ

[79] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៤៧-៥៧។

[80] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៥៨-៦១។ *សូមមើលផងដែរ* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥០២-៥០៤។ *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២៥។

[81] ដូចបានពិភាក្សាក្នុងឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៥៨ ជើងទំព័រ១៥៥។ *សូមមើលផងដែរ* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥០២។ សម្រាប់ឧទាហរណ៍បន្ថែមអំពីការសំអាងរបស់ ស.ច.ស.ជ លើភ័ស្តុតាងរបស់ ប្រាក់ យុត សម្រាប់ព័ត៌មានទូទៅ*សូមមើល ខ.* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ៧៩, ៨៨, ៩១, ១០៦-១០៧, ១១០, ១១៦, ១១៨, ១៣៣, ១៣៥, ១៦៣, ១៦៧, ១៨០, ១៨២, ១៨៤, ១៩២-១៩៣, ២១០, ២១៦, ២២១-២២២, ២៣២-២៣៤, ២៧៣, ២៩២, ២៩៣, ៣២៣-៣២៤, ៤៤៣, ៤៤៦, ៤៥៦-៤៥៧, ៤៦៤, ៤៧៥, ៤៨៤, ៥១៣-៥២២, ៥៣៥-៥៣៧, ៥៥៤, ៥៥៩-៥៦០, ៥៨១, ៥៨៤, ៦៥៣, ៦៨៩-៦៩១, ៦៩៤, ៦៩៦-៦៩៨, ៧១៧-៧២១, ៧២៣-៧២៤, ៨២៩, ៨៩០, ១០២៥។

[82] ផ្នែកទាំងមូលនៃដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបានផ្តោតលើឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងស្រុកកំពង់សៀម ដែលជាកន្លែង ប្រាក់ យុត គឺជាលេខានោះ មិនបាននិយាយអំពីភ័ស្តុតាងរបស់គាត់នៃការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលរូបគាត់

ប្រកាន់គ្រាន់តែបានថ្លែងថា ភ័ស្តុតាងរបស់ ប្រាក់ យុត ទាក់ទងនឹងការចូលរួមរបស់ អោ អាន នៅក្នុង "ការប្រព្រឹត្តលើ*អង្គហេតុមួយចំនួន*" ទំនងជាមិនអាចជឿជាក់បាន ដោយសារតែការមិនពេញចិត្តរបស់ ប្រាក់ យុត ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារការចាប់ខ្លួនប្ដីរបស់គាត់[83]។ មិនមានការបញ្ជាក់បន្ថែមអ្វីទៀតត្រូវបានផ្ដល់ឱ្យនោះទេ ទាក់ទងនឹងថាតើភ័ស្តុតាងជាក់លាក់ដែលឆ្លើយដាក់ណាមួយដែលមិនគួរឱ្យជឿបាន។ បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ បានបង្ហាញអំពីការបញ្ជាក់បន្ថែមលើភ័ស្តុតាងរបស់ ប្រាក់ យុត ដែលថា អោ អាន បានណែនាំអ្នកនៅក្រោមបង្គាប់ឱ្យដកហូត និង ដាក់ជំនួសវិញនូវប្រធានឃុំ និងប្រធានភូមិដែលកំពុងកាន់កាប់តំណែងឱ្យជីកប្រូស និងសម្លាប់ពួកចាមចោល ក៏ដូចជាប្រជាជនធម្មតាដែលត្រូវបានសង្ស័យថាមិនស្មោះត្រង់ ហើយថាបញ្ជាទាំងនេះត្រូវបានគេអនុវត្តតាម[84]។

29. ចម្លើយតបរបស់ អោ អាន បានបកស្រាយខុសអំពីគោលជំហររបស់ ស.ព.អ ចំពោះ ប្រាក់ យុត ដោយអះអាងថា ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ទទួលស្គាល់ថា ប្រាក់ យុត មិនមានភាពគួរឱ្យជឿបាន អាស្រ័យហេតុដូច្នេះ បានបង្កប់ន័យថា ស.ព.អ បាននិយាយថា មិនមានភ័ស្តុតាងណាមួយរបស់គាត់គួរឱ្យជឿជាក់បាននោះទេ[85]។ ការណ៍នេះមិនមែនជាករណីនេះទេ។ ផ្ទុយទៅវិញ ស.ព.អ បានបង្ហាញយ៉ាងស៊ីសង្វាក់គ្នាថា ភ័ស្តុតាងជាច្រើនរបស់ ប្រាក់ យុត គឺទាំង*បញ្ជាក់បន្ថែមដោយ* និងទាំង*បញ្ជាក់បន្ថែមអំពី* ភាពទាំងស្រុងនៃភ័ស្តុតាងនៅក្នុងសំណុំរឿង

---

និងអ្នកផ្សេងទៀតបានទទួលពី អោ អាន នោះទេ។ *សូមមើល ឧ.* កង្វះខាតការរៀបរាប់ក្នុងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ <u>គោកព្រីង៖</u> កថាខណ្ឌ៣៣២-៣៣៦ (ជើងទំព័រ១០២៥-១០៤២) - ភ័ស្តុតាងរបស់ ប្រាក់ យុត ត្រូវបានដកស្រង់ ដើម្បីគាំទ្រដល់ទីតាំងរបស់ទីកន្លែងនោះតែប៉ុណ្ណោះ (ជើងទំព័រ១០២៥) ហើយអង្គហេតុដែលថា មនុស្សត្រូវបានសម្លាប់នៅបឹងធំ (ជើងទំព័រ ១០៣០)។ <u>វត្តអង្គញ្ញដី៖</u> កថាខណ្ឌ ៣៨៧-៣៩១ (ជើងទំព័រ ១២៤១-១២៦៣)។ <u>ទួលបេង៖</u> កថាខណ្ឌ៣៩២-៣៩៦ (ជើងទំព័រ ១២៦៤-១២៨៥) <u>ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖</u> ១៦៥-១៧៩ (ជើងទំព័រ ៣៨២-៤៤១), ៣៩៧-៤០៨ (ជើងទំព័រ ១២៨៦-១៣២១) ៥០០-៥០១ (ជើងទំព័រ ១៤២១) - ភ័ស្តុតាងរបស់ ប្រាក់ យុត ត្រូវបានដកស្រង់តែដើម្បីគាំទ្រដល់ចម្លើយដែលថា ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សមួយចំនួនមិនត្រូវបានបង្ខំឱ្យរៀបការទេ (ជើងទំព័រ ៣៨២)។

[83] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥០២ (គួសបញ្ជាក់បន្ថែម) ៥០៤។ *សូមមើលផងដែរ* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៥៨-៦១។

[84] ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៦០-៦១។

[85] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២៥។

និងថា មានមូលហេតុនីមួយៗដើម្បីផ្តល់នូវទម្ងន់យ៉ាងច្រើនទៅដល់ភ័ស្តុតាងនោះ[86]។ ស.ព.អ ក៏បានទទួលស្គាល់ផងដែរថា ប្រាក់ យុត បានដកយកមកវិញនូវផ្នែកខ្លះនៃភ័ស្តុតាងពីមុនៗរបស់គាត់ ស្តីពីបញ្ហារបស់ អោ អាន ឲ្យកំទេចពួកចាមទាំងអស់ ក៏ប៉ុន្តែបានពន្យល់ពីមូលហេតុដែលចំណុចនោះមិនអាចជឿជាក់បាន[87]។ ពាក់ព័ន្ធបន្ថែមទៀតទៅនឹងភ័ស្តុតាងរបស់ ប្រាក់ យុត, អោ អាន គ្រាន់តែបានយោងអំណះអំណាងដែលគាត់បានធ្វើពីមុន[88] ដូច្នេះ ស.ព.អ នឹងពឹងផ្អែកលើអំណះអំណាងផ្ទាល់របស់គាត់ ដែលបានលើកឡើងរួចជាស្រេចនៅកន្លែងផ្សេងនៅក្នុងចម្លើយតបវិញម្តង[89] និងបញ្ជាក់ឡើងវិញថា ទោះបីជាសាក្សីម្នាក់អាចគួរឲ្យជឿជាក់បាននៅក្នុងទិដ្ឋភាពមួយនៃភ័ស្តុតាងរបស់គាត់ក៏ដោយ ការណ៍នោះមិនបានធ្វើយុត្តិកម្មដល់ការបដិសេធចោលនូវភ័ស្តុតាងទាំងស្រុងរបស់គាត់នោះទេ[90]។

30. អោ អាន ក៏បានចោទប្រកាន់ដោយខុសឆ្គងផងដែរថា ស.ព.អ ខកខានមិនបានផ្តល់ភ័ស្តុតាងថា ស.ច.ស.ជ មានកំហុសយ៉ាងដូចម្តេច ទាក់ទងនឹងសេចក្តីថ្លែងរបស់គាត់ដែលថា ភាពតឹងរ៉ឹង និងភាពសម្ងាត់នៃរបបនោះ ហើយនិងអានុភាពនៃពេលវេលាអាចនឹងប៉ះពាល់ដល់រឿងរ៉ាវរបស់សាក្សី[91]។ ដើម្បីឲ្យបានច្បាស់លាស់ ស.ព.អ មិនជំទាស់ទេថា ទាំងនេះតាមពិតទៅជាកត្តាដែលអាចប៉ះពាល់ដល់ភាពអាចទុកចិត្តបាននៃរឿងរ៉ាវមួយចំនួន។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ បានលើកឡើងយ៉ាងច្បាស់ថា ជាជាងការពិនិត្យទៅលើខ្លឹមសារនៃរឿងរ៉ាវ និងកម្រិតខ្ពស់នៃការបញ្ជាក់បន្ថែមពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងចំណុចមានប្រៀបជាងជាច្រើន ដើម្បីកំណត់រកមើលថាតើចរិកលក្ខណៈនៃរបប ឬពេលវេលាកន្លងទៅ

---

[86] *សូមមើល ឧ.* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ កថាខណ្ឌ១៩-២០, ២៧-២៩, ៣៩៩-៤០៦។ ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៥៩-៦១, ៨២, ៨៥។ ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៣៥-៣៨, ៥៣, ៦១-៦៣, ៦៥-៦៦, ៧៣-៧៦។

[87] *សូមមើល ឧ.* ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ កថាខណ្ឌ៦៣-៧១, ៤០៧-៤០៨។

[88] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២៥។

[89] ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៣៥-៣៨, ៥៣, ៦១-៦២, ៦៥-៦៧, ៧៣-៧៥។

[90] *សូមមើល ឧ.* ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៣៤ ជាពិសេសប្រភពដែលបានដកស្រង់ក្នុងជើងទំព័រ៦១។

[91] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២៦។

បានប៉ះពាល់ដល់ភ័ស្តុតាងដែលបានឆ្លើយដាក់ អោ អាន ដែរ ឬទេ ស.ច.ស.ជ ទំនងជាបានបដិសេធភ័ស្តុតាងបែបដូច្នេះជាទូទៅ ដោយសារតែកត្តាអស់ទាំងនេះ[92]។ ផ្ទុយទៅនឹងអំណះអំណាងរបស់ អោ អាន វាមិនមែនជា "ការឈានមកផ្តល់សំអាងហេតុបែបនេះ" ក្នុងការដែលនិយាយថា ស.ច.ស.ជ បានសន្និដ្ឋានតាមប្រភេទភ័ស្តុតាងអំពីការចូលរួមនៅក្នុងឧក្រិដ្ឋកម្មរបស់ អោ អាន ជាការមិនអាចទុកចិត្តបាននោះទេ[93] ជាពិសេស ដោយសារតែ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ នៅក្នុងកថាខណ្ឌដែលរងការជំទាស់ ឬនៅកន្លែងផ្សេងៗទៀត ដែលភ័ស្តុតាងជាក់លាក់ណា ដែលត្រូវបានប៉ះពាល់ដោយសារកត្តាទាំងនេះ[94]។ លើសពីនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ខកខានមិនបានយោងភ័ស្តុតាងសំខាន់ៗជាច្រើនដែលបានឆ្លើយដាក់ អោ អាន កុំថាឡើយពិភាក្សានៅក្នុងប្រភេទណាមួយនៃការវាយតម្លៃមានសំអាងហេតុ តាមករណីនីមួយៗ ថាតើហេតុអ្វី បានជាភ័ស្តុតាងបែបដូច្នោះមិនបានធ្វើឱ្យមានការជឿជាក់[95]។ វាជាការគួរឱ្យកត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទ

---

[92] **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៦២-៦៤។

[93] **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ២៦។

[94] **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥០៦។ *សូមមើលផងដែរ* កថាខណ្ឌ៤៦០, ៥២៨។

[95] ឧទាហរណ៍ ក្រៅពីឧទាហរណ៍រៀបរាប់ ដែលផ្តល់ជូននៅក្នុងជើងទំព័រ ៨២ *យោងខាងលើ* នៃអវត្តមានគួរឱ្យកត់សម្គាល់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់អំពីភ័ស្តុតាងណាមួយរបស់ ប្រាក់ យុត ដែលដាក់កំហុសលើ អោ អាន ចំពោះឧក្រិដ្ឋកម្មនៅក្នុងស្រុកដែល គាត់ធ្វើជាលេខានោះ ដីកាសម្រេចលើកលែងចោទប្រកាន់ស្រដៀងគ្នាដែរមិនបានរៀបរាប់អំពីភ័ស្តុតាងរបស់ ញ៉ែម ចេន ដែលបានដាក់កំហុសលើ អោ អាន នោះទេ រួមទាំង (១) ភ័ស្តុតាងដែលថា ញ៉ែម ចេន បានចូលរួមប្រជុំនៅវត្តតាម: ដែលដឹកនាំដោយ អោ អាន ដែលនៅក្នុងការប្រជុំនោះ អ្នកចូលរួមត្រូវបានណែនាំឱ្យប្រើល្បិចបញ្ឆោតអតីតមន្ត្រីរបប លន់ នល់ ឱ្យប្រាប់ពីមុខតំណែងពីមុនរបស់ពួកគេ បន្ទាប់មកបញ្ជូនពួកគេទៅសម្លាប់ [*សូមមើល* ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.១៦៦-១៧២ និងការខ្វះខាតការរៀបរាប់ណាមួយអំពីភ័ស្តុតាងនេះ រួមទាំងក្នុងការពិភាក្សាអំពីតំបន់ ៤១ វត្តតាម: និងការទទួលខុសត្រូវរបស់ អោ អាន នៅក្នុងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣៩-២៦២ (ជើងទំព័រ ៦៨៩-៧៩០), ៣៥០-៣៥៩ (ជើងទំព័រ ១០៥៥-១០៩៨) ៤៩៤-៥១០ (ជើងទំព័រ ១៤១៦-១៤២៨) ៥៤៩-៥៥១]។ (២) ភ័ស្តុតាងដែល ញ៉ែម ចេន បានទៅកាន់មន្ទីរសន្តិសុខមិត្តសុប (គ) ដើម្បីប្រមូលរបាយការណ៍អំពីការសម្លាប់ ដែលគាត់បានយកមកឱ្យ អោ អាន [*សូមមើល* ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៥៨-៥៩, ៧៥-៧៧ និងការមិនមានការរៀបរាប់ណាមួយអំពីភ័ស្តុតាងនេះ រួមទាំងក្នុងការពិភាក្សាអំពីតំបន់ ៤១ មន្ទីរសន្តិសុខមិត្តសុប (គ) និងការទទួលខុសត្រូវរបស់ អោ អាន នៅក្នុងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣៩-២៦២ (ជើងទំព័រ៦៨៩-៧៩០) ៣២៣-៣៣១ (ជើងទំព័រ ៩៩២-១០២៤), ៤៩៤-៥១០ (ជើងទំព័រ ១៤១៦-១៤២៨), ៥៤៩-៥៥១]។ និង (៣) ភ័ស្តុតាងដែល អោ អាន បានបញ្ជា តាអួន ឱ្យចាប់មនុស្ស

ប្រកាន់បានដកស្រង់យ៉ាងច្រើនសម្បើមនូវភ័ស្តុតាងផ្សេងៗទៀតពីសាក្សីដូចគ្នា ដែលភ័ស្តុតាងឆ្លើយដាក់របស់ពួកគាត់ត្រូវបានមើលរំលង ដោយបានបញ្ជាក់ថា ភ័ស្តុតាងរបស់ពួកគាត់ត្រូវបានគេពិចារណាថាគួរឲ្យជឿទុកចិត្តបាន ទោះបីជាមានភាពសម្ងាត់នៃរបបនោះ ឬ ពេលវេលាកន្លងផុតទៅយ៉ាងណាក៏ដោយ[96]។

## ខ. ការវិភាគអង្គហេតុរបស់ អោ អាន មិនត្រឹមត្រូវ និងមិនគួរឲ្យជឿជាក់បាន

31. ការប៉ុនប៉ងរបស់ អោ អាន ដើម្បីគាំទ្រដល់សំអាងហេតុមិនសមហេតុផលរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ គឺមិនត្រឹមត្រូវ និងមិនគួរឲ្យជឿជាក់បាន នៅពេល ដែលភ័ស្តុតាងត្រូវបានពិចារណានៅក្នុងភាពពេញលេញរបស់វា។

### ១. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ពាក់ព័ន្ធនឹងតួនាទីរបស់ អោ អាន នៅក្នុងការចាប់ខ្លួន និងការសម្លាប់ចោល មិនសមហេតុផល

32. មិនមានអ្នកវិនិច្ឆ័យអង្គហេតុដ៏សមហេតុផលណាម្នាក់អាចសន្និដ្ឋានថា "មានភ័ស្តុតាងដ៏តិចតួចបំផុតមែនទែន ដែលបង្ហាញការចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ពី អោ អាន"[97] នោះទេ ឬក៏ថា "ភ័ស្តុតាងបង្ហាញថា អោ អាន [...] អាចមានការពាក់ព័ន្ធនឹងការចេញបញ្ជាឲ្យចាប់ និង

---

[*សូមមើល*ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៧១-៧៣ និងការមិនមានការរៀបរាប់ណាមួយអំពីភ័ស្តុតាងនេះ រួមទាំងនៅក្នុងការពិភាក្សាអំពីតំបន់ ៤១ និងការទទួលខុសត្រូវរបស់ អោ អាន នៅក្នុងឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣៩-២៦២ (ជើងទំព័រ ៦៨៩-៧៩០) ៤៩៤-៥១០ (ជើងទំព័រ ១៤១៦-១៤២៨) ៥៤៩-៥៥១]។

[96] ឧទាហរណ៍ ក្រៅពីការពឹងផ្អែកយ៉ាងច្រើនរបស់ដីកាសម្រេចលើកលែងចោទប្រកាន់លើភ័ស្តុតាងរបស់ ប្រាក់ យុត នៅពេលដែលដីកានេះមិនបានទម្លាក់កំហុសលើ អោ អាន ដោយផ្ទាល់ (ចម្លើយរបស់ ប្រាក់ យុត ត្រូវបានយោង ១៩២ដង នៅក្នុងជើងទំព័រនៃដីកាសម្រេចលើកលែងចោទប្រកាន់) ភ័ស្តុតាងរបស់ ញ៉ែម ចេន ត្រូវបានផ្អែកលើ ៨២ដង រួមទាំងភ័ស្តុតាងរបស់គាត់ដែលថា នៅពេលដែល ញ៉ែម ចេន សួរ អោ អាន ថាតើ គាត់អាណិតអ្នកដទៃទៀត ឬទេ អោ អាន បានប្រាប់គាត់ថា "ប្រសិនបើខ្ញុំមិនគោរពតាមបញ្ជាទេនោះ គេនឹងសម្លាប់ខ្ញុំដែរ"។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣២៨, ៤៩៦។

[97] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥៤៩។ ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៦៧។

សម្លាប់មនុស្សមួយចំនួនតូច"[98]។ នៅក្នុងការប៉ុនប៉ងដើម្បីគាំទ្រការសន្និដ្ឋានពីដីកាសម្រេចលើកលែងចោទប្រកាន់នេះ អោ អាន បានពិនិត្យនូវភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង តាមរបៀបម្តងមួយៗ ដែលនេះជាវិធីសាស្ត្រមិនត្រឹមត្រូវ ដែលត្រូវបានច្រានចោលយ៉ាងច្បាស់ក្រឡែតរួចមកហើយដោយ អ.ជ.ត.ក[99]។ ដូចដែលគាត់ធ្លាប់បានឆ្លងកាត់កិច្ចដំណើរការនីតិវិធីទាំងនេះ អោ អាន បានទទូចថា សាក្សីដាច់ដោយឡែកពីគ្នា និងភ័ស្តុតាងផ្នែកៗដាច់ដោយឡែក គួរត្រូវបានពិចារណាដាច់ដោយឡែកពីគ្នា[100] ខណៈដែលមិនគិតអំពីការបញ្ជាក់បន្ថែមយ៉ាងលើសលប់ ដែលបានផ្តល់ឲ្យពីសំណាក់រឿងរ៉ាវនានាយ៉ាងជាប់លាប់របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូប ដែលបង្ហាញពីតួនាទី ការទទួលខុសត្រូវ និង ការចូលរួមចំណែកនៅក្នុងឧក្រិដ្ឋកម្មរបស់ អោ អាន នៅក្នុងភូមិភាគកណ្តាល[101]។

33. ជាឧទាហរណ៍ អោ អាន បានប៉ុនប៉ងដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ទាក់ទងនឹងការចាប់ខ្លួន និងការសម្លាប់ចោលដោយផ្អែកលើមូលដ្ឋានដែលថា ប្រាក់ យុត, យូ វ៉ាន់ និង ញ៉ែម ចេន មិនមែនជាសាក្សីដែលគួរឲ្យជឿជាក់បាននោះទេ[102]។ គាត់បានចោទប្រកាន់ថា ភ័ស្តុតាងរបស់ ប្រាក់ យុត មិនអាចជឿជាក់បានទេពីព្រោះគាត់បានព្យាយាមដើម្បីទំលាក់កំហុសទៅលើ អោ អាន[103] ថា យូ វ៉ាន់ គ្រាន់តែថាតាមភ័ស្តុតាងរបស់ ប្រាក់ យុត តែប៉ុណ្ណោះ[104] ហើយថា ភ័ស្តុតាងរបស់ ញ៉ែម ចេន មិនគួរត្រូវបានទទួលយក

---

[98] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៩៧។ ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ៦៧។

[99] សំណុំរឿង០០២-ឯកសារ **F36** សាលដីកាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៤១៩។

[100] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ៣១-៣២ *ដាក់បញ្ចូលដោយការយោង* ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៣-៦៦, ៦៩-៧០, ១២០-១២៥, ១៤៦-១៥០ និង ឯកសារ **D351/6** ចម្លើយតបរបស់ អោ អាន ទៅនឹងដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ២៨៤, ៣០៨-៣១២។

[101] **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៥៥-៨៨។

[102] **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ៣២ *ដកស្រង់* ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៣-៦៦, ៦៩-៧០។

[103] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៣-៦៤។

[104] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៥-៦៦។

នោះទេពីព្រោះគាត់នៅក្មេងពេកនៅក្នុងពេលនៃព្រឹត្តិការណ៍ពាក់ព័ន្ធនោះ មិនអាចផ្តល់នូវភ័ស្តុតាងដែលជឿទុកចិត្តបានទេ[105]។ ការទិះទៀនទាំងនេះ គឺមិនមានអង្គសេចក្តី ដោយផ្អែកលើមូលហេតុជាច្រើនដែលបានរៀបរាប់យ៉ាងពិស្តារនៅកន្លែងផ្សេងៗ[106] ក៏ប៉ុន្តែពួកវាខកខាន ជាពិសេសមិនពាក់ព័ន្ធទៅនឹងវិធីដែលរឿងរ៉ាវដាច់ដោយឡែក បានបញ្ជាក់បន្ថែមឲ្យគ្នាទៅវិញទៅមក៖ អោ អាន មិនដែលបានព្យាយាមដោះស្រាយជាមួយនឹងសំណួរ ថាតើ របៀបដែលរឿងរ៉ាវដាច់ដោយឡែកពីគ្នាទាំងបី អាចនឹងត្រូវគ្នាយ៉ាងខ្លាំងយ៉ាងណានោះទេ ដរាបណាវាពិត។

34. អោ អាន ក៏ព្យាយាមកាត់បន្ថយគុណភាពភ័ស្តុតាង ដែលបង្ហាញថា អោ អាន បានបញ្ជាឲ្យមានការចាប់ខ្លួន និងការសម្លាប់។ អោ អាន ចង្អុលបង្ហាញថា ការចោទប្រកាន់ជាច្រើននៃការបញ្ជាឲ្យសម្លាប់គឺមកពី ប្រាក់ យុត, យូ វ៉ាន់ និង ញ៉ែម ចេន[107] ប៉ុន្តែបានមើលរំលងការពិតដែលថា កែ ពេជ្រវណ្ណៈ, តុយ មៀច និង សូ សារ៉េន ក៏បានផ្តល់ភ័ស្តុតាងផ្ទាល់ថា អោ អាន បានចេញបញ្ជាឲ្យសម្លាប់ផងដែរ[108]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំមួយនាក់ ដែលបានផ្តល់ការរៀបរាប់ផ្ទាល់ និងស៊ីសង្វាក់អំពីការចេញបញ្ជាដោយផ្ទាល់របស់ អោ អាន ឲ្យសម្លាប់មនុស្សបញ្ជាក់គ្នាទៅវិញទៅមក។ ពួកវាត្រូវបានបញ្ជាក់បន្ថែមទៀតដោយភ័ស្តុតាងដែលថា អោ អាន បានគំរាមសម្លាប់នៅក្នុងការប្រជុំជាសាធារណៈដ៏ធំមួយ[109] បានអួតអាងអំពីការសម្លាប់ដែលបាន

---

[105] ឯកសារ **D360/5/1** បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦៩-៧០។

[106] ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៣៥-៣៩, ៤២។

[107] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៣២។

[108] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧០។

[109] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា ឆ.៦ [“ខ្ញុំឃើញ តាអាន ដំបូងនៅពេល តាអាន ទៅដល់នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ គាត់បានកោះហៅបុគ្គលិកថ្នាក់តំបន់ប្រហែល ៣០០នាក់ ឲ្យចូលរួមប្រជុំ នៅវត្តតាមៈ នៅឃុំជ្រៃវៀន ហើយគាត់ប្រកាសប្រាប់ថា គាត់គឺជាប្រធានតំបន់ ៤១ថ្មី។ [...] ក្នុងការប្រជុំនោះគាត់បានប្រាប់ថា “ពួកអាមុនវើ លន់ នល់ ជិះសេះ លន់ នល់” ដែលមានន័យថា ពួកអ្នកមុនស្អប់របប លន់ នល់ តែក្រោយពេលពួកគេទទួលបានជ័យជម្នះ ពួកគេធ្វើដូចរបប លន់ នល់ ដដែល។ គាត់បន្ថែមថា “ចាប់ពីថ្ងៃនេះទៅ នឹងស្លាប់ច្រើនជាង បេ-៥២ ចាក់ទៅទៀត!”។”]។ ឯកសារ **D219/498** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា ឆ.៥, ៧ [“នៅពេលប្រជុំ តាអាន និយាយថា ពីពេលនេះទៅនឹងមានមនុស្សស្លាប់ច្រើនជាង បេ ៥២ ទៅទៀត។ [...] តាអាន ក្រោកឈរ នៅចំពោះមុខទាំងអស់គ្នាហើយនិយាយថា “ពីថ្ងៃនេះតទៅនឹងមានមនុស្សស្លាប់ជាង បេ ៥២ចាក់ទៅទៀត ដោយសារតែសង្គ្រាមអត់ស្នូរ” មានន័យថា បេ៥២ មានសម្លេងឮខ្លាំង ប៉ុន្តែសង្គ្រាមដែលគាត់និយាយនៅពេលនោះ ពុំមានសូរសម្លេងអ្វីឡើយ”]។

ធ្វើឡើងរួចហើយនៅក្នុងការប្រជុំមួយផ្សេងទៀត[110] បានទៅពិនិត្យមើលមន្ទីរសន្តិសុខដើម្បីធានាថា បទបញ្ជាឱ្យសម្លាប់ត្រូវបានអនុវត្ត[111] បានទទួលរបាយការណ៍អំពីការសម្លាប់[112] និងបានអមដំណើរឡានដឹកអ្នកទោសដែលក្រោយមកត្រូវបានសម្លាប់[113]។ អោ អាន ខ្លួនឯងផ្ទាល់ក៏បាន

---

[110] ឯកសារ **D6.1.700** កំណត់ហេតុស្តាប់ចម្លើយ សេង ស្រ៊ុន ឆ.៦ ["ប្រធានកងឈ្មោះ ហឿន បានប្រាប់ប្រជាជនក្នុងភូមិឱ្យមកចូលរួមក្នុងអង្គមេទ្ធិញ ដែលមាន ប្រធានតំបន់មកចូលរួម ហើយនិយាយថា គ្រប់គ្នាត្រូវតែចូលរួម។ នៅក្នុងមេទ្ធិញនោះ អាន និយាយថា អ្នកមុនៗត្រូវបានសម្លាប់ ពីព្រោះពួកគេជាមនុស្សឃោរឃៅ តែតាមពិត ពួកគាត់មិនមែនជាមនុស្សឃោរឃៅដូចអ្នកមកថ្មីនោះទេ។"]។

[111] ឯកសារ **D219/732** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៣០-៤០ ["សៈ ពេលដែលគេដឹកទៅ ពីមន្ទីរតំបន់ទៅមន្ទីរសន្តិសុខគរ តើអ្នកដែលគេដឹកទៅដើរដោយសេរីទេ? ឆៈ គេហៅដាក់ឡាន ប្រាប់ថា ដូចទៅរៀន ទៅប្រជុំអ៊ីចឹង។ ពេលទៅដល់មន្ទីរសន្តិសុខគរ គេហៅចូលបន្ទប់ម្តងមួយ រួចគេចាប់ចង។ [...] បន្តិចមកគេយកទៅវៃចោលតែម្តងនៅយប់នោះឬយប់បន្ទាប់។ សៈ អ្នកណាជាអ្នកបញ្ជាឱ្យសម្លាប់ពួកនោះ? ឆៈ បញ្ជាចេញពីប្រធានតំបន់ទៅ។ សៈ ប្រធានតំបន់ ឈ្មោះអី? ឆៈ គាត់ឈ្មោះ តាអាន។ សៈ សម្រាប់លោកផ្ទាល់ លោកមានវត្តមាននៅពេលដែល តាអាន បញ្ជាឱ្យសម្លាប់អ្នកទោសទាំងនោះទេ? ឆៈ ខ្ញុំនៅផ្ទាល់ដែរ ពេលតាអាន បញ្ជាឃោធា ឲ្យទៅប្រាប់សន្តិសុខ។ [...] សៈ តើ តាអាន ដែលទៅការិយាល័យមន្ទីរសន្តិសុខនោះទេ? ឆៈ ទៅ។ សៈ តើលោកទៅជាមួយគាត់ទេ? ឆៈ ខ្ញុំទៅ។ សៈ តើ តាអាន ទៅធ្វើអី ទៅកន្លែងនោះដើម្បីអី? ឆៈ គាត់ចង់ដឹងថា បញ្ជាទៅធ្វើអស់ ឬមិនអស់ គាត់ចង់ដឹងតែប៉ុណ្ណឹង។"]។

[112] ឯកសារ **D219/120** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ឆ.១៤, ២៧ ["នៅពេលដែលខ្ញុំផ្ទេរការងារឲ្យ ស៊ី ជាអនុប្រធានខ្ញុំហើយ ខ្ញុំមិនបានចាប់អារម្មណ៍ និងតាមដានទៅមើលថា ជនជាតិចាមទាំងនោះត្រូវយកទៅសម្លាប់នៅកន្លែងណាមួយនៅទួលបេងនោះទេ។ ស៊ី គ្រាន់តែរាយការណ៍ប្រាប់មកខ្ញុំថា បានអនុវត្តបញ្ជារួចរាល់ហើយ។ ចំណែកខ្ញុំក៏បានរាយការណ៍បន្តទៅថ្នាក់តំបន់ ថាការងារនោះបានអនុវត្តរួចរាល់ហើយ។"]។ ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន ឆ.៥៨-៥៩ ["សៈ លោកដឹងទេថា តើ តាអាន ឬក៏ តាអួន គាត់មានបានទទួលរាយការណ៍ពីខាងមន្ទីរសន្តិសុខទាំងអស់ហ្នឹងប្រាប់អំពីថា ឥឡូវនៅមន្ទីរសន្តិសុខដំណើរការដល់នេះ សម្លាប់មនុស្សស្អីៗចេះហើយ? ឆៈ ខ្ញុំអ្នកទៅទទួល គាត់បញ្ជាថា កូនឯងទៅ "គ" ទៅយកឯកសារ ហើយខ្ញុំយកជូន [អោ អាន]។ គាត់ហៅថា នីរសារឯងទៅសន្តិសុខ "គ" ហើយជិះម៉ូតូទៅនឹងគេទៅ ហើយក្រដាសហ្នឹង គេដាក់ស្រោមជិតឈឹង។ សៈ តើលោកដឹងថា សំបុត្រហ្នឹង មានព័ត៌មានអីខ្លះទេ? ឆៈ គ្រាន់តែដឹងថា ព័ត៌មានពីសន្តិសុខហ្នឹង ព័ត៌មានអីខ្ញុំមិនដឹងទេ ប៉ុន្តែវាគ្មានរឿងអីទេ តាអាន និយាយ គឺរឿងរបាយការណ៍អ្នកស្លាប់ហើយ។ ខ្ញុំទៅជាមួយគាត់ នៅក្បែរគាត់ កំពុងហូបបាយ គាត់ថា មនុស្សប៉ុន្មានត្រូវគេយកទៅរៀនសូត្ររួចហើយ មិនបានប៉ុន្មានទៀតទេ សម្រេចផែនការយើងហើយ។"]។

[113] ឯកសារ **D219/226** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា ឆ.២៤ ["បន្ទាប់ពីការបោសម្អាតពួកបូព៌ានៅខែមេសា ឆ្នាំ១៩៧៨ ខ្ញុំបានឃើញ សមមិត្ត ម៉យ ដែលជាដៃស្តាំរបស់ តាអាន អ្នកទទួលខុសត្រូវខាងចាប់ចង ជិះម៉ូតូទៅពីមុខឡានពីរគ្រឿង ដែលឡានទី១គឺ ឡានហ្ស៊ីពអាខី ដែល តាអាន ជិះនៅក្នុងនោះ និងឡានទី២ គឺឡានកាត់១ចិន ដែលមានអ្នកទោសភូមិភាគបូព៌ា ប្រហែល ២០ នាក់ នៅក្នុងនោះ។"]។ ឯកសារ **D219/498** កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា ឆ.១៤-១៦ ["ខ្ញុំចាំថា ពេលខ្ញុំដើរទៅហូបបបរនៅភូមិពង្រ ខ្ញុំឃើញ ឈ្មោះម៉យ ជិះម៉ូតូពីមុខ ឡានហ្ស៊ីបរបស់តាអាន គឺឡានហ្ស៊ីប អា-២ និងឡានមួយទៀតគឺឡានកាត់ចិន (៤x៤) ដឹកអ្នកទោសដែលជាកម្មាភិបាលបូព៌ា។ ប្រហែលជាមានម៉ូតូមួយគ្រឿងទៀត នៅពីក្រោយឡានកាត់កាត់

សារភាពថា គាត់បានប្រាប់ កែ ពក ថា គាត់បានអនុវត្តបញ្ជាសម្លាប់ទាហាន លន់ នល់ (ទោះបីជាគាត់អះអាងថា គាត់បានកុហក កែ ពក និងថាតាមពិតនោះគាត់បានការពារទាហានទាំងនោះក៏ដោយ)[114]។

35. ភ័ស្តុតាងអំពី អោ អាន ចេញបញ្ជាឲ្យសម្លាប់មនុស្ស គឺពិតជាមានច្រើនលើសលប់។ មិនមានអ្នកវិនិច្ឆ័យអង្គហេតុសមហេតុផលណាដែលពិចារណាលើភ័ស្តុតាងទាំងមូល បានខកខានមិនបានសន្និដ្ឋានថា អោ អាន បានបញ្ជាឲ្យសម្លាប់មនុស្សនោះទេ។

## ២. ការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មក្នុងភូមិភាគកណ្តាល

36. ដីកាសម្រេចលើកលែងចោទប្រកាន់បានសម្រេចខុសថា អោ អាន បានមកដល់ភូមិភាគកណ្តាលនៅពាក់កណ្តាលឆ្នាំ ១៩៧៧ នៅពេលដែលការបោសសម្អាតភាគច្រើនត្រូវបានបញ្ចប់[115]។ ការសន្និដ្ឋាននេះផ្អែកជាចំបងលើភ័ស្តុតាងតែមួយចំណែកតូច ដែលមិនត្រូវបានរៀបចំឡើងតាមការត្រួតពិនិត្យរបស់តុលាការ (ស្វ័យជីវប្រវត្តិរបស់ កែ ពក) ដែលមិនស៊ីសង្វាក់គ្នាទៅនឹងភ័ស្តុតាង

---

ចិននោះ។ កាលនោះ ផ្លូវនោះពុំមានក្រាលកៅស៊ូដូចឥឡូវទេ វាជាផ្លូវដីធម្មតា។ ខ្ញុំបានឃើញអ្នកទោសនៅក្នុងឡានកាត់កាត់ចិននោះ តិចជាង ២០នាក់ ហើយពួកគេគឺជាកម្មាភិបាលស្លិតក្នុងឯកសណ្ឋានពណ៌ខ្មៅថ្មីៗ ហើយដៃរបស់ពួកគេជាប់ចំណង។ [...] សៈ តើតាអាន ជិះឡានសហ្ស៊ីបជាមួយអ្នកណា? ឆៈ មានអ្នកបើកឡានម្នាក់ និងអង្គរក្សមួយចំនួនជិះឡាន ហ្ស៊ីបអា-២ ជាមួយតាអាន។ នៅពីក្រោយឡានហ្ស៊ីបរបស់ តាអាន មានឡានកាត់កាត់ចិនដែលដឹកអ្នកទោសតិចជាង ២០នាក់ ដែលអ្នកទោសទាំងនោះគឺជាកម្មាភិបាលភូមិភាគបូព៌ា។ សៈ ចុះលោកចំណាំអ្នកទោសទាំងនោះទេ? ឆៈ អត់ទេ គ្រាន់តែដឹងថាជាកម្មាភិបាលបូព៌ា ហើយប្អូនថ្លៃប្រុសខ្ញុំបានឃើញគេសម្លាប់កម្មាភិបាលបូព៌ា។ គាត់បានឃើញគេបណ្តើរកម្មាភិបាលបូព៌ាទាំងនោះ ជាជួរយកទៅសម្លាប់នៅវត្តរកាគយ ក្នុងស្រុកកងមាស។”]។

[114] ឯកសារ **D103.1.39** បទសម្ភាសន៍ អោ អាន ដោយ VOA ជាភាសាខ្មែរ *ជនសង្ស័យនៃអំពើឃោរឃៅនិយាយថាគាត់ ‘មិនភ័យនឹងតុលាការ យមបាល’* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ EN 00750163 [“គាត់បាននិយាយថា ទោះបីជាគាត់ត្រូវបានបញ្ជាដោយមេបញ្ជាការយោធាខ្មែរក្រហម កែ ពក ឲ្យសម្លាប់ពួកអ្នកគាំទ្ររបប លន់ នល់ ក៏ដោយ ក៏គាត់បានលាក់ពួកគេក្នុងចម្ការរបស់សមូហភាព។ [...] គាត់បានប្រាប់ថ្នាក់លើរបស់គាត់ថា គាត់បាន ‘សម្អាត’ ឬ បានសម្លាប់ពួកគេ ‘ប៉ុន្តែពួកគេនៅចំការ។”]។

[115] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩៤, ៥០៨។

ភាគច្រើនលើសលប់នៅក្នុងសំណុំរឿងនេះ[116]។ នៅក្នុងចម្លើយតបរបស់គាត់ អោ អាន បាននិយាយឡើងវិញនូវការការលើកឡើងមិនត្រឹមត្រូវរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថា ភ័ស្តុតាងរបស់ កែ ពក លើចំណុចនេះត្រូវបានបញ្ជាក់ត្រឹមត្រូវ[117] ប៉ុន្តែតាមពិតនោះ ភ័ស្តុតាងភាគច្រើនដែលដីកាសម្រេចលើកលែងចោទប្រកាន់បានដកស្រង់ ជាការបញ្ជាក់បន្ថែម សម្រាប់កាលបរិច្ឆេទនៃការមកដល់ក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧ បង្ហាញថា កម្មាភិបាលភូមិភាគ និរតីបានមកដល់ក្នុងភូមិភាគកណ្តាលនៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ១៩៧៧ ហើយភ័ស្តុតាងដែល នៅសេសសល់ជាច្រើនទៀតនោះគឺមិនច្បាស់ ឬមិនមានបញ្ហាញពីចំណុចនេះទេ[118]។ ដោយពិចា រណាលើភាពពេញលេញនៃភ័ស្តុតាង ការពឹងផ្អែកច្រើនលើសលប់ និងគ្មានការពន្យល់របស់ដីកា សម្រេចលើកលែងចោទប្រកាន់លើស្វ័យជីវប្រវត្តិរបស់ កែ ពក គឺមិនសមហេតុសមផលឡើយ។

37. សំខាន់ជាងនេះទៀត កាលបរិច្ឆេទច្បាស់លាស់អំពីការមកដល់របស់ អោ អាន ក្នុងភូមិភាគ កណ្តាល មិនមែនជាការកំណត់អំពីកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ទេ ដោយសារ ភ័ស្តុតាងបង្ហាញថា ឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងស្ថិតក្រោមការត្រួត ពិនិត្យ ការគ្រប់គ្រង និងការចូលរួមយ៉ាងសកម្មរបស់គាត់[119]។ ការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្ម ត្រូវបានបង្ហាញតាមរយៈភ័ស្តុតាងផ្ទាល់ ជាឧទាហរណ៍ អំពីការគំរាមកំហែង ការបញ្ជា និងការត្រួតពិនិត្យការសម្លាប់របស់ អោ អាន[120]។ យ៉ាងសមហេតុផលនោះ ប្រសិនបើ អោ អាន បានមកដល់ក្នុងភូមិភាគកណ្តាលនៅពាក់កណ្តាលឆ្នាំ ១៩៧៧ ដូចដែលបានសន្និដ្ឋាន នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់មែននោះ វានឹងមានន័យថា ឧក្រិដ្ឋកម្មដែលត្រូវបាន ចោទប្រកាន់បានកើតឡើងក្រោយកាលបរិច្ឆេទនេះ។

38. អោ អាន អះអាងថា ការកំណត់ពេលវេលានៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ គឺជាបញ្ហាសំខាន់ ពីព្រោះ "មានភាពពាក់ព័ន្ធនឹងការវាយតម្លៃថាតើ អោ អាន មានតួនាទីសំខាន់ដែរឬទេ នៅក្នុង

---

[116] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៩៤។ សម្រាប់ការពិភាក្សាបន្ថែមទៀតនៃភ័ស្តុតាងលើ ចំណុចនេះ *សូមមើល* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧៣-៧៨។

[117] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៣៦។

[118] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧៦-៧៧។

[119] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧៩-៨៦។

[120] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៧-៧២។

ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត នៅពេលប្រៀបធៀបជាមួយនឹងមន្ត្រីខ្មែរក្រហមផ្សេងទៀត ដែលទំនងជាបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មនៅពេញមួយរបបខ្មែរក្រហម"[121]។ អំណះអំណាងនេះមើលរំលងចំណុចដែលថា វាគឺភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទៅវិញទេ ដែលជាបញ្ហាសំខាន់នោះ មិនមែនរយៈពេលដែលប្រើដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះទេ។ ចារីម្នាក់ដែលបណ្តាលឲ្យមានការស្លាប់មនុស្ស ១០.០០០នាក់ ក្នុងរយៈពេលពីឆ្នាំ មិនទទួលខុសត្រូវច្រើនជាងអ្នកដែលបណ្តាលឲ្យមានចំនួនមនុស្សស្លាប់ដូចគ្នាក្នុងរយៈពេលពីរខែនោះឡើយ។

39. អោ អាន ក៏បានសង្កត់ធ្ងន់លើការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា ភ័ស្តុតាងដែលលម្អៀងទៅរការចោទប្រកាន់ អោ អាន គឺមិនគួរឲ្យទុកចិត្តបានឡើយ[122]។ អោ អាន លើកឡើងថា សចសជ បានសន្និដ្ឋានថា ភ័ស្តុតាងនេះមិនគួរឲ្យទុកចិត្តបានទេ ព្រោះសាក្សីដែលពាក់ព័ន្ធ "ទំនងជាឆ្លើយដាក់បន្ទុក អោ អាន ពីព្រោះពួកគេមានការពាក់ព័ន្ធដោយផ្ទាល់នឹងអំពើទាំងនេះ"[123]។ ការព្យាយាមរបស់ អោ អាន ក្នុងការបង្ហាញពីយុទ្ធនាការឧក្រិដ្ឋ ជាពិសេសអំពើប្រល័យពូជសាសន៍ចាម ថាបានប្រឌិតឡើងដោយលេខាស្រុក ប្រាក់ យុទ្ធ ខកខានមិនបានពន្យល់ពីមូលហេតុដែលឧក្រិដ្ឋកម្មដូចគ្នានេះ បានកំពុងកើតមានឡើងនៅក្នុងស្រុកទាំងអស់ផ្សេងទៀតក្នុងតំបន់ ៤១។ ជាងនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានធ្វើការសន្និដ្ឋានណាមួយថា ប្រាក់ យុត បានឆ្លើយដាក់កំហុសលើ អោ អាន ដើម្បីធ្វើឲ្យខ្លួនគាត់រួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះទេ ផ្ទុយទៅវិញ ដីកានោះបានសន្និដ្ឋានថា ប្រាក់ យុត បានដាក់កំហុសលើ អោ អាន ពីព្រោះគាត់មិន "ពេញចិត្តនឹងបដិវត្តន៍ ដោយសារការចាប់ខ្លួនប្តី និងការដកតំណែង"[124]។ ក្រៅពីភាពមិនទំនងនៃអំណះអំណាងនេះលើអង្គហេតុរបស់វានោះ វាក៏ខកខានមិនបានពន្យល់ពីមូលហេតុដែល ប្រាក់ យុត បានរង់ចាំអស់ជាច្រើនឆ្នាំ - និងសម្រាប់ការស្តាប់ចម្លើយបញ្ជាក់ឡើងវិញដែលមិនធ្លាប់កើតមាន - ដើម្បីចាប់ផ្តើមធ្វើយុទ្ធនាការសងសឹករបស់គាត់ ប្រឆាំង

---

[121] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤០។

[122] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤១*ដកស្រង់* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០២-៥០៤។

[123] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤១។

[124] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥០៤។ *សូមមើលផងដែរ* ឯកសារ **D6.1.722** កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត ធ.៤។

នឹង អោ អាន និង "បដិវត្តន៍"[125]។ សំខាន់ជាងនេះទៀត ការសន្និដ្ឋាននេះមិនស្របគ្នាទៅនឹងការរកឃើញនានាដទៃទៀត នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់។ ដីកាសម្រេចលើកលែងចោទប្រកាន់ ជាឧទាហរណ៍ បានរកឃើញថា មានគោលនយោបាយមជ្ឈិមរបស់កម្ពុជាប្រជាធិបតេយ្យឲ្យ "កម្ទេច" ចាមទាំងអស់ ដែលបទបញ្ជា និងសេចក្តីណែនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ជូនបន្តចុះមកក្រោមតាមរយៈ "ប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយ នៅក្នុងខ្សែសង្វាក់នៃការបញ្ជា" និងថា ជនជាតិចាមភាគច្រើននៅក្នុងស្រុកកំពង់សៀម និងស្រុកកងមាស តាមពិតនោះ ត្រូវបានសម្លាប់[126]។ ផ្អែកលើការរកឃើញទាំងអស់នោះ ភ័ស្តុតាងដែលគួរឲ្យជាក់តែមួយគត់ ប្រាក់ យុត គួរតែបានផ្តល់ឲ្យនោះគឺ ការរៀបរាប់ដែលគាត់ពិតជាបានផ្តល់ឲ្យហើយ - នោះគឺ អោ អាន បានបញ្ជូនបទបញ្ជានានាទៅឲ្យគាត់សម្លាប់មនុស្ស ចំណែករូបគាត់បញ្ជូនមកថ្នាក់ក្រោមរបស់គាត់ ដែលជាអ្នកអនុវត្តបទបញ្ជាទាំងនោះ[127]។

## ៣. តួនាទីរបស់ អោ អាន នៅថ្នាក់ភូមិភាគ

40. អោ អាន គាំទ្រការសន្និដ្ឋានមិនសមហេតុផលរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថារូបគាត់មិនមានតួនាទីក្នុងការស្រេចថ្នាក់ភូមិភាគទេ ដោយបានមើលរំលងភ័ស្តុតាងពាក់ព័ន្ធ។ កំណត់ហេតុស្តាប់ចម្លើយ បាន សៀក ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានដកស្រង់ដើម្បីគាំទ្រការបង្ហាញរបស់ខ្លួនអំពី កែ ពក ថាជាស្ថាបនិកតែម្នាក់គត់នៅក្នុងការបោសសម្អាតភូមិភាគកណ្តាល[128] អានដូចខាងក្រោម៖

> ភូមិភាគគ្រប់គ្រងដោយ កែ ពក ជាលេខា។ កែ ពក គឺជាប្រធានគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ដែលមានគណៈតំបន់ បីនាក់ គឺតាអាន (មកពីភូមិភាគនិរតី លេខាតំបន់ ៤១) ស៊ីម (មកពីភូមិភាគនិរតី លេខាតំបន់ ៤៣) អឿន (មនុស្សរបស់ភូមិភាគកណ្តាល លេខាតំបន់ ៤២) និងប្រធានមន្ទីរភាគ។ តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជាការបោសសំអាតជាដើម

[125] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៥៩។

[126] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦១។

[127] ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦១។

[128] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ 159.

ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍នេះ នៅក្នុងការប្រជុំសំងាត់របស់គេ[129]។

41. ដីកាសម្រេចលើកលែងចោទប្រកាន់ បានកែរការដកស្រង់នេះ តាមវិធីដែលប្តូរអត្ថន័យរបស់វា (ដោយបានដកការយោងនានាទៅ អោ អាន និងលេខាតំបន់ផ្សេងទៀតចេញ)[130] ប៉ុន្តែ នៅពេលអានវាទាំងមូល មិនមានការអានដ៏សមហេតុផលណានៃភស្តុតាងនេះ ដែលមិនបង្ហាញពីតួនាទីសំខាន់របស់ អោ អាន ក្នុងការធ្វើការសម្រេចនានាទាក់ទងនឹងការបោសសំអាតក្នុងភូមិភាគកណ្តាលនោះទេ។ អោ អាន ដាក់បញ្ចូលអំណះអំណាងពីមុនរបស់គាត់ ដែលថា ភស្តុតាងអំពីការកាត់តំណែងភូមិភាគកណ្តាល និងការចូលរួមចំណែកក្នុងការធ្វើការសម្រេចថ្នាក់ភូមិភាគកណ្តាលទាក់ទងនឹងការបោសសំអាតនេះ គឺមិនគ្រប់គ្រាន់នោះទេ[131]។ សពអ បានឆ្លើយតបទៅនឹងអំណះអំណាងទាំងនេះនៅកន្លែងផ្សេងទៀត[132] ប៉ុន្តែ ភស្តុតាងរបស់ បាន សៀក ត្រូវបានបញ្ជាក់ដោយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីប្រាំពីរនាក់ ដែលបានលើកឡើងថា អោ អាន គឺជាអនុលេខាភូមិភាគកណ្តាល[133] និងហេតុដូច្នេះ ជាអ្នកដែលគេរំពឹងថាបានចូលរួមក្នុងការធ្វើការសម្រេចបែបនោះ។

42. ទោះជាយ៉ាងណា ការរកឃើញដែលថា អោ អាន បានជាប់ពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចថ្នាក់ភូមិភាគកណ្តាល ទាក់ទងនឹងការបោសសំអាតនោះ មិនចាំបាច់សម្រាប់ការសន្និដ្ឋានថា អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះទេ សូម្បីតែគាត់គ្រាន់តែទទួលបញ្ជាពី កែ ពក ដោយមិនមានការចូលរួមក្នុងការរៀបចំគោលនយោបាយថ្នាក់ភូមិភាគក្តី ការអនុវត្តរបស់គាត់នូវបទបញ្ជាទាំងនេះ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលគាត់បានត្រួតពិនិត្យ គឺមានកល្ខណៈគ្រប់គ្រាន់ច្បាស់លាស់ ដើម្បីដាក់គាត់ឲ្យស្ថិតក្នុងប្រភេទនោះ។ ភស្តុតាងដ៏គួរឲ្យជឿ

---

[129] ឯកសារ **D107/15** កំណត់ហេតុស្តាប់ចម្លើយ បាន សៀក KH 00800954។

[130] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៩។

[131] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤៦-៤៧។

[132] ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៩-៨៣។

[133] ឯកសារ **D360/9** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៩-៨៣។

ជាក់បង្ហាញដែលថា គាត់ទំនងជាបានជាប់ពាក់ព័ន្ធក្នុងការធ្វើការសម្រេចថ្នាក់ភូមិភាគកណ្តាល គ្រាន់តែបញ្ជាក់បន្ថែមទៅលើការសន្និដ្ឋានដែលថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ច. សចសជ មានកំហុសអង្គច្បាប់ដោយខកខានមិនបានវាយតម្លៃភាពធ្ងន់ធ្ងរ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានចោទប្រកាន់

43. ដូចមានបង្ហាញនៅក្នុងផ្នែកទី III ខាងលើ សចសជ មានកំហុសអង្គច្បាប់ដោយខកខានមិនបានវាយតម្លៃយុត្តាធិការបុគ្គលរបស់តុលាការលើ អោ អាន តាមបទដ្ឋានតម្រូវ និងដោយការខកខានមិនបានចេញយោបល់មានសំអាងហេតុ[134]។ ដើម្បីសម្រេចថាតើ ជនត្រូវចោទគឺជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" តាមកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ឬទេនោះ សចស ត្រូវតែវាយតម្លៃទាំង "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" និង "កម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ"[135]។ ទោះបីជាមានការបញ្ជាក់យ៉ាងច្បាស់ថានេះគឺជាបទដ្ឋានជាធរមាន[136] និងមិនបានបង្ហាញអំពីហេតុផលច្បាស់លាស់[137]ដើម្បីចាកចេញពីបទដ្ឋានជាធរមាននេះក៏ដោយ សចសជ គ្រាន់តែបដិសេធមិនអនុវត្តតាមបទដ្ឋានជាធរមាននេះ[138]

---

[134] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤៩-៥០, ៥៥-៥៦, ៦២។ *សូមមើលផងដែរ*ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៥, ៩៥, ៩៩។

[135] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤ *ដកស្រង់* សំណុំរឿង០០១-ឯកសារ **E188** សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង *ឌុច* កថាខណ្ឌ ២២។

[136] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៤។

[137] *សូមមើល, ឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **E313** សំណុំរឿង០០២/០១ សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១០, ៧១៩ (មិនមានហេតុផលច្បាស់លាស់ដើម្បីចាកចេញពីយុត្តិសាស្ត្រពីមុនឡើយ)។

[138] *សូមមើលជាទូទៅ* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ *និងជាពិសេស* កថាខណ្ឌ ២ (បានបដិសេធមិន "ចាត់បទល្មើស [] សរសេរបញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវនោះទេ" ដែលចំណុចទាំងពីរនេះចាំបាច់យ៉ាងខ្លាំងដើម្បីកំណត់ពីធាតុផ្សំ*អំពើឧក្រិដ្ឋ* និង *ចេតនាឧក្រិដ្ឋ* សម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល និងដើម្បីកំណត់ថាតើពួកគេបានបំពេញតាមលក្ខខណ្ឌតម្រូវ ឬទេ)។ តាមពិតនោះ ក្រោយពីបញ្ជាក់អំពីបទដ្ឋានជាធរមានត្រង់កថាខណ្ឌ ៤២៤ ស.ច.ស.ជ មិនបានលើកឡើងជាថ្មីម្តងទៀតអំពី "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់" ឡើយ រហូតដល់ជើងទំព័រ

ឬធ្វើការសន្និដ្ឋានជាមូលដ្ឋានដ៏ចាំបាច់ណាមួយលើ "អត្ថិភាពនៃបទល្មើស" និង "ភវនីយភាព" នៃ "ការទទួលខុសត្រូវព្រហ្មទណ្ឌ" របស់ អោ អាន ចំពោះពួកវាឡើយ[139]។ ចំណុចនេះនាំឱ្យមានកំហុសអង្គច្បាប់ ដែលធ្វើឱ្យការវាយតម្លៃលើយុត្តាធិការរបស់ សចសជ គ្មានសុពលភាព។

44. ផលប៉ះពាល់ជារួមនៃកំហុសនេះ និងកំហុសផ្សេងទៀត ដែលបានរៀបរាប់ក្នុងបណ្តឹងឧទ្ធរណ៍របស់ សពអ គឺថា នៅពេលដែលពិចារណាលើយុត្តាធិការបុគ្គលរបស់តុលាការ ចំពោះ អោ អាន ថាជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សចសជ មានកំហុសផ្នែកអង្គច្បាប់ ដោយការខកខាន ជាពិសេស មិនបានវាយតម្លៃអត្ថិភាពនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានចោទប្រកាន់ ភាពធ្ងន់ធ្ងររបស់វា ឬការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះការអនុវត្តវា[140]។ ជាលទ្ធផល សចសជ បានដកអំពើប្រល័យពូជសាសន៍ចេញពីការវាយតម្លៃលើយុត្តាធិការបុគ្គលទាំងអស់យ៉ាងមានប្រសិទ្ធភាព។

45. វិធីមួយក្នុងចំណោមវិធីនានាដែលអំពើប្រល័យពូជសាសន៍ត្រូវបានចែកដាច់ដោយឡែកពីឧក្រិដ្ឋកម្មអន្តរជាតិ គឺថា រដ្ឋចំនួន ១៤៩ រួមទាំងប្រទេសកម្ពុជាផង បានផ្តល់សច្ចាប័នអនុសញ្ញាប្រល័យពូជសាសន៍ រដ្ឋនីមួយៗបានប្តេជ្ញាទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋកម្មនេះ។ អោ អាន អះអាងថា វាមិនសមហេតុផលទេក្នុងការសន្មតថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មានបំណងបំពេញកាតព្វកិច្ចនៃអនុសញ្ញាប្រល័យពូជសាសន៍នេះ ដើម្បីផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ដោយតវ៉ាថា ការធ្វើដូច្នេះនឹងតម្រូវឱ្យ អ.វ.ត.ក ចោទប្រកាន់ចារីរាប់រយ ឬរាប់ពាន់នាក់ចំពោះឧក្រិដ្ឋកម្មនេះ[141]។ ប៉ុន្តែចំណុចនេះ មិនមែនជាអំណះអំណាងរបស់ សពអ ដែលបានបង្ហាញថា អនុសញ្ញាប្រល័យពូជសាសន៍បានកំណត់កាតព្វកិច្ចឱ្យរដ្ឋនានា ធានាថា

---

ចុងក្រោយ (ជើងទំព័រលេខ ១៤៥២) ដែលក្នុងនោះ គាត់ជាថ្មីម្តងទៀតទទួលស្គាល់ថា ការសន្និដ្ឋានបែបនោះចាំបាច់។ គាត់មិនបានធ្វើការសន្និដ្ឋានណាមួយលើការទទួលខុសត្រូវជាលក្ខណៈបុគ្គលឡើយ។

[139] *សូមមើល ឧទាហរណ៍* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២៦ (ការសម្រេចជាឯកច្ឆ័ន្ទ)។

[140] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៤៩-៥០, ៥៥-៥៦, ៦២។ *សូមមើលផងដែរ* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៥, ៩៥, ៩៩។

[141] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៧-៦៥។

ឧក្រិដ្ឋកម្មនេះត្រូវបានរារាំងតាមរយៈការផ្ដន្ទាទោសចារីសំខាន់ៗ[142]។ ផ្ទុយទៅនឹងការសន្និដ្ឋានរបស់ អោ អាន[143] មិនមានអ្វីមិនសមហេតុផលឡើយក្នុងការសន្មតថា រាជរដ្ឋាភិបាលកម្ពុជាមានបំណងបំពេញកាតព្វកិច្ចអនុសញ្ញារបស់ខ្លួន ឬថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានប្ដេជ្ញាសម្រេចឲ្យបានគោលបំណងរបស់អនុសញ្ញានេះ ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដោយការផ្ដន្ទាទោសចារីសំខាន់ៗ។ សពអ មិនដែលបានតវ៉ាថា រាល់ទាហានថ្មើរជើងទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ត្រូវតែផ្ដន្ទាទោសនោះទេ[144] ប៉ុន្តែ អោ អាន មិនមែនជាទាហានថ្មើរជើងនោះទេ។ ផ្ទុយទៅវិញ គាត់បានដឹកនាំតំបន់ទាំងមូល[145] និងមិនមែនគ្រាន់តែតំបន់ណាមួយនោះទេ។ តំបន់ ៤១ គឺជាផ្នែកមួយនៃចំណុចសំខាន់ពីដើមមករបស់ជនជាតិចាម និងជាមណ្ឌលនៃអំពើប្រល័យពូជសាសន៍ចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[146]។ ចាមជាច្រើនពាន់នាក់បានស្លាប់នៅទីនោះក្រោមការបញ្ជារបស់ អោ អាន ឲ្យកំណត់អត្តសញ្ញាណ និងសម្លាប់ចាមទាំងអស់[147]។ នៅពេលដែល អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងថា អ.វ.ត.ក នឹងកាត់សេចក្ដីជនទាំងឡាយណាដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ពួកគេប្រាកដជាមានបំណងថា អ្នកអនុវត្តសំខាន់នៃអំពើប្រល័យពូជាសាសន៍ នឹងមិនទទួលបាននិទណ្ឌភាពបន្តទៀតទេ។

46. នៅក្នុងចម្លើយតបរបស់គាត់ អោ អាន មិនបានជំទាស់ទៅនឹងភាពពាក់ព័ន្ធនៃអំពើប្រល័យពូជសាសន៍ទៅនឹងការវាយតម្លៃយុត្តាធិការបុគ្គលឡើយ ដោយគាត់គ្រាន់តែមិនអើពើនឹងកំហុសជាមូលដ្ឋាន និងការកំណត់លក្ខណៈដីកាលើកលែងចោទប្រកាន់ខុស។ ឧទាហរណ៍ ផ្ទុយទៅនឹង

---

[142] *សូមមើល ឧទាហរណ៍* ឯកសារ **D359/3/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩៨ (តវ៉ាថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើជនទាំងឡាយណាដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាចាំបាច់រួមបញ្ចូលទាំងមេដឹកនាំដែលដើរតួនាទីសំខាន់ក្នុងការអនុវត្តអំពើប្រល័យពូជសាសន៍)។ *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៧។

[143] *សូមមើល* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន ជារួម កថាខណ្ឌ ៥៧-៦១។

[144] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៧។

[145] ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៤២, ៥១០។

[146] *សូមមើល, ឧទាហរណ៍* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤១-១៤៦, ៣០៧, ៤០៩-៤១៨, ៤៩៨។

[147] *សូមមើល, ឧទាហរណ៍* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤១-១៤៦, ៣០៧, ៤១០-៤២០, ៤៩៨។

ការអះអាងរបស់ អោ អាន មិនមានកថាខណ្ឌណាមួយក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលគាត់ដកស្រង់ "បានពិភាក្សា" ដែលតិចតួចបានធ្វើការសន្និដ្ឋាន អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ ឬការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះពួកវា រួមទាំង អំពើប្រល័យពូជសាសន៍ផង[148]។ អោ អាន ថែមទាំងទទួលស្គាល់ថា សចសជ មិនបានធ្វើការ សន្និដ្ឋាននានាអំពីចេតនាប្រល័យពូជសាសន៍[149] ដែលត្រូវការចាំបាច់សម្រាប់ការវាយតម្លៃណាមួយ អំពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ជាងនេះទៀត ទោះបីជា ស.ច.ស.ជ អាចមានវិធានការ តាមឆន្ទានុសិទ្ធិដើម្បីធ្វើការពិចារណា និងថ្លឹងថ្លែងអំពី "កត្តាជាច្រើនពាក់ព័ន្ធនឹងយុត្តាធិការ បុគ្គល"[150] ក៏ដោយ គាត់ *មិន* មានឆន្ទានុសិទ្ធិក្នុងការមិនអើពើទាំងស្រុងចំពោះ អ្វីដែលគាត់យល់ ស្របថាគឺជាការសន្និដ្ឋានដែលត្រូវការចាំបាច់សម្រាប់ការវាយតម្លៃនេះ ឬដើម្បីគាំទ្រដល់ ការប្រៀបធៀបកម្រិតពាក់ព័ន្ធនៃការទទួលខុសត្រូវរបស់ ឌុច និង អោ អាន នោះឡើយ[151] ខណៈ ដែលដកចេញការពិចារណាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អោ អាន ចំពោះអំពើប្រល័យ ពូជសាសន៍ប្រឆាំងនឹងជនជាតិចាម។

[148] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ១១ (ជើងទំព័រ ២១, ២៤) ៥០ (ជើងទំព័រ ១០៣) ៥៥។ ស្រដៀងគ្នានេះ ស.ព.អ មិនបានអះអាងថា ស.ច.ស.ជ មិនបាន "ពិចារណា" ទោះបីជាមិនគ្រប់គ្រាន់ "អំពើប្រល័យពូជាសាសន៍ដែលបានចោទប្រកាន់" ឬ "តួនាទីសំខាន់របស់ អោ អាន នៅក្នុងអំពើនោះ" នោះឡើយ (*ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៥។ *សូមមើល* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៩-៤១៨) ប៉ុន្តែថា ស.ច.ស.ជ មិនបានធ្វើការវាយតម្លៃទាល់តែសោះអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៃអំពើប្រល័យពូជាសាសន៍ ឬការទទួលខុសត្រូវរបស់ អោ អាន ចំពោះអំពើនោះ។ ទោះជាយ៉ាងណា សូម្បីតែត្រង់ចំណុចដែល ស.ច.ស.ជ និយាយអំពីកត្តាជាមូលដ្ឋានពាក់ព័ន្ធជាសក្តានុពលចំពោះចំណុចមួយក្នុងចំណោមចំណុចទាំងឡាយ គាត់ខកខានមិនបានធ្វើសូម្បីតែសំអាងហេតុខ្លីណាមួយ ដែលការសន្និដ្ឋានចុងក្រោយមួយអាចផ្អែកលើវាយ៉ាងត្រឹមត្រូវឡើយ កាន់តែតិចជាងនេះទៀតនោះ ខកខានមិនបានវាយតម្លៃការសន្និដ្ឋានបែបនោះក្នុងបរិបទនៃចំណុចទាំងនេះ។ *សូមមើល ឧទាហរណ៍* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៩-៤២០។

[149] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៣។

[150] *ផ្ទុយពីនេះ* ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៥៦។

[151] *សូមមើល ឧទាហរណ៍* ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៤៣-៥៥៣។ ស.ច.ស.ជ បានធ្វើការបែងចែកជាច្រើនដែលមិនមានការពន្យល់ និងមិនគាំទ្រដោយច្បាប់រវាងប្រភេទនៃ "ការចូលរួម"។ ជាឧទាហរណ៍ ដីកាសម្រេចលើកលែងចោទប្រកាន់មិនមានការពន្យល់ណាមួយចំពោះមូលហេតុដែល ឌុច "បានចូលរួមដោយផ្ទាល់" ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួន ដែលធ្វើឱ្យគាត់ "ទទួលខុសត្រូវច្រើន" ជាង អោ អាន ដែលបានប្រើមនុស្សរបស់គាត់ដើម្បីបណ្តាលឱ្យមានការស្លាប់មនុស្សរាប់ម៉ឺននាក់នោះឡើយ។

**ឆ. គោលជំហររបស់ សពអ លើដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា គោរពតាមកិច្ចព្រមព្រៀង អ.វ.ត.ក គោលបំណងរបស់អ្នកតាក់តែងច្បាប់ វិធានផ្ទៃក្នុង និងយុត្តិសាស្ត្រ អ.វ.ត.ក**

47. អោ អាន តវ៉ាថា ដោយសារតែ សចស មិនបានដាក់ការខ្វែងយោបល់របស់ពួកគេលើយុត្តាធិការបុគ្គលទៅកាន់ អ.ប.ជ ដូច្នេះ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ការសម្រេចរបស់ អជតក ក្នុងសំណុំរឿង ០០១ មិនអាចអនុវត្តបានទេ ប្រសិនបើ អបជ មិនអាចរកសម្លេងភាគច្រើនដែលត្រូវការដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ឬសម្រេចថា មិនមាន សចស ណាម្នាក់មានកំហុសនោះ[152]។ ប៉ុន្តែ អោ អាន ខកខានមិនបានពន្យល់ថា មូលហេតុអ្វីបានជាលទ្ធផលគួរតែខុសពីនេះនោះ។ ជាខ្លឹមសារ នីតិវិធីទាំងពីរដូចគ្នា។ ខុសគ្នាតែមួយគឺថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ដែល សចស មានសិទ្ធិធ្វើដូច្នេះ[153] ប្រហែលជាអាចកាត់បន្ថយដំណើរការ។

48. សពអ ទទួលស្គាល់ថា ទាំងមាត្រា ៧(៤) និងការសម្រេចរបស់ អជតក សំដៅលើសេណារីយ៉ូដែល សចស អនុវត្តតាមនីតិវិធីដោះស្រាយវិវាទតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលមិនត្រូវបានប្រើនៅពេលដែល សចស បានចេញដីកាដំណោះស្រាយរបស់ខ្លួនដាច់ដោយឡែកពីគ្នាក្នុងរឿងក្តីនេះ[154]។ តាមការសន្និដ្ឋាន សចស បានជ្រើសរើសចេញដីកាដំណោះស្រាយដាច់ដោយឡែក

---

[152] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៦៤, ៦៦ (*ដែលបានយោង* សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥)។

[153] ស.ច.ស មានជម្រើសដាក់វិវាទទៅ អ.ប.ជ ឲ្យសម្រេច ប៉ុន្តែវាមិនតម្រូវដាច់ខាតថាពួកគាត់ត្រូវតែធ្វើដូច្នោះឡើយ។ មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងថា៖ "ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូបក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាការខ្វែងយោបល់គ្នាត្រូវដោះស្រាយដោ" ដោយ អ.ប.ជ។ *សូមមើលផងដែរ* វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង ដែលទទួលស្គាល់ថា កិច្ចស៊ើបសួរ ឬសេចក្តីសម្រេចអាចត្រូវបានធ្វើឡើងដោយចៅក្រមស៊ើអង្កេតតែម្នាក់ ប្រសិនបើការខ្វែងយោបល់គ្នាមិនត្រូវបានបញ្ជូនទៅកាន់ អ.ប.ជ ឲ្យរកដំណោះស្រាយនោះទេ ប្រសិនបើរយៈពេលរង់ចាំ ៣០ថ្ងៃ ត្រូវបានបំពេញ (គិតរាប់ចាប់ពីកាលបរិច្ឆេទនៃការខ្វែងយោបល់គ្នាត្រូវបានធ្វើកំណត់ហេតុ)។

[154] ត្រង់នេះ ស.ច.ស បានជ្រើសរើសធ្វើកំណត់ហេតុការខ្វែងយោបល់របស់ពួកគាត់តាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង រង់ចាំរយៈពេលតម្រូវ ៣០ថ្ងៃ ដែលបានកំណត់ដោយវិធាន ៧២(៣) និងបន្ទាប់មកចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដែលខ្វែងយោបល់គ្នាចំពោះបញ្ហាយុត្តាធិការបុគ្គល។ *សូមមើល ឧទាហរណ៍* ឯកសារ **D360** ដីកាបញ្ជូនទៅជំនុំជម្រះ កថាខណ្ឌ ១, ១៦ ["នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ស.ច.ស បានចុះកមណត់ហេតុករណីខ្វែងយោបល់គ្នាទាក់ទងនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា"]។ *កត់សម្គាល់ថា* ទាំងឯកសារ **D359** និងទាំង

ពីគ្នាក្នុងសំណុំរឿង ០០៤/២ ពីព្រោះតែពួកគាត់មិនចង់ពន្យារពេលកិច្ចដំណើរការនីតិវិធី។ ពួកគាត់ទំនងជាបានមើលឃើញពីអត្ថប្រយោជន៍នៃការអនុញ្ញាតឱ្យភាគីនានាបានបញ្ចេញយោបល់លើបញ្ហាយុត្តាធិការបុគ្គល ដោយការផ្តល់អំណះអំណាងបន្ថែមដែលអាចជួយដល់ អបជ ក្នុងការធ្វើសេចក្តីសម្រេចមួយគ្រប់ជ្រុងជ្រោយ[155]។ ទោះជាយ៉ាងណា លទ្ធផលចុងក្រោយនៃនីតិវិធីណាមួយទាំងពីរនេះ គឺដូចគ្នា ដោយតួនាទីរបស់ អបជ ត្រូវដោះស្រាយបញ្ហាជាក់លាក់ គឺ យុត្តាធិការបុគ្គលដែល សចស ខ្វែងយោបល់គ្នា[156]។ ហេតុដូច្នេះ មាត្រា ៧(៤) និងសេណារីយ៉ូដែលប្រមើលឃើញក្នុងសាលដីកាបណ្តឹងសាទុក្ខសំណុំរឿង០០១ អាចអនុវត្តបាន ប្រសិនបើមានដីកាពីផ្ទុយគ្នា ក្រោយពេលដែល អបជ បានពិចារណាលើរាល់បញ្ហាទាំងអស់រួចហើយ។

49. អំណះអំណាងរបស់ អោ អាន ថា ការបកស្រាយរបស់ សពអ នៃវិធាន ៧៧(១៣)(ខ) ផ្តល់អំណាច និងការគ្រប់គ្រងច្រើនទៅឱ្យ សចស ម្នាក់ ជាងម្នាក់ផ្សេងទៀត[157] ខកខានមិនបានពិចារណាអំពីកង្វល់ដែលអ្នកតាក់តែងច្បាប់មាន នៅពេលដែលពួកគេបង្កើត អ.វ.ត.ក នេះ និងដំណោះស្រាយដែលពួកគេឯកភាពគ្នា ក្រោយពីការចចារជាច្រើនមក[158]។ ដំណោះស្រាយនោះវិធានស្តីពីសម្លេងភាគច្រើនលើសលប់ ត្រូវបានអនុវត្តជាពិសេសដើម្បីធ្វើឱ្យរឿងក្តីដំណើរការទៅ

---

ឯកសារ **D360** ត្រូវបានចេញនៅថ្ងៃទីទី១៦ ខែសីហា ឆ្នាំ២០១៨ ដូច្នេះ បានបំពេញតាមរយៈពេលរង់ចាំ ៣០ថ្ងៃ ដែលតម្រូវដើម្បីធ្វើ ក្រោយពេលចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា។

[155] ប្រសិនបើ ស.ច.ស ផ្ទុយទៅវិញ បានជ្រើសរើសដាក់ការខ្វែងយោបល់គ្នារបស់ពួកគេទៅកាន់ អ.ប.ជ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ហើយ អ.ប.ជ ក្រោយមកបានធ្វើសេចក្តីសម្រេចមួយ នោះភាគីនានាមិនមានឱកាសបញ្ចេញទស្សនៈរបស់ខ្លួនឡើយ។ *សូមមើល* វិធានផ្ទៃក្នុង៧២(៤)(ឃ) ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍"។

[156] អ.ជ.ត.ក បានកត់សម្គាល់ថា នៅពេលដែលនីតិវិធីដោះស្រាយវិវាទត្រូវបានប្រើ "តួនាទីរបស់អង្គបុរេជំនុំជម្រះត្រូវសម្រេចពីបញ្ហាខ្វែងគំនិតគ្នារបស់សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត" *សូមមើល* សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥។

[157] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៦៥។

[158] របាយការណ៍របស់អគ្គលេខាស្តីពីការជំនុំជម្រះខ្មែរក្រហម UN Doc. A/57/769 ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ("របាយការណ៍របស់អគ្គលេខា") កថាខណ្ឌ ១០(ង), ១៣, ១៦-១៧, ២០-២៣, ២៧-៣០, ៧៩។ David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទីបី ភាគ III កែសម្រួលដោយ M. Cherif Bassiouni ឆ្នាំ២០០៨ ("អត្ថបទរបស់ Scheffer") ទំព័រ២៣០-២៣១, ២៣៣-២៣៤, ២៤៦-២៤៧។

មុខ[159]។ អបជ បានតម្កល់ដំណោះស្រាយនេះយ៉ាងស៊ីសង្វាក់ ដោយបានអនុញ្ញាតបន្តកិច្ចស៊ើបសួរនៅពេលណាដែលមានការខ្វែងយោបល់គ្នា ហើយ អបជ មិនអាចរកសម្លេងភាគច្រើនលើសលប់ដែលត្រូវការដើម្បីធ្វើសេចក្តីសម្រេចបាន[160]។ ដូចដែលបានកត់សម្គាល់ដោយលោក David Scheffer ដែលជាអ្នកបានចូលរួមក្នុងការបង្កើតតុលាការនេះ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបអង្កេតត្រូវបានជាប់គាំងគឺ ប្រសិនណាបើអង្គបុរេជំនុំជម្រះសម្រេចដោយសម្លេងភាគច្រើនលើសលប់ថា វាគួរតែចប់"[161]។

50. ដូចដែលបានរៀបរាប់ពេញលេញជាងនេះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ សពអ បទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុង ប្រវត្តិចរចារដែលបានកត់ត្រាពីចេតនារបស់អ្នកតាក់តែងកិច្ចព្រមព្រៀង អ.វ.ត.ក និង យុត្តិសាស្ត្រ អ.វ.ត.ក ទាំងអស់នេះ កំណត់ថា ប្រសិនបើ អបជ ខកខានមិនអាចឯកភាពគ្នាតាមលក្ខខណ្ឌតម្រូវដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយណាមួយ ឬប្រសិនបើ អបជ សន្និដ្ឋានថា មិនមាន សចស ណាម្នាក់មានកំហុសទេនោះ រឿងក្តីត្រូវតែបញ្ជូនទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាចោទប្រកាន់ដែលចេញដោយ សចសអ[162]។ លទ្ធផលបែបនេះមិនរំលោភលើគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* នោះទេ ដោយសារតែមិនមាន "ភាពមិនច្បាស់លាស់ផ្នែកនីតិវិធីធ" ត្រូវដោះស្រាយ ផ្លូវទៅមុខត្រូវបានបញ្ជាក់ដោយប្រភពទាំងអស់នេះ[163]។ លើសពីនេះទៀត ការសម្រេចនានានៅក្នុងសំណុំរឿង០០២ ប្រឆាំងទៅនឹងការអះអាងរបស់ អោ អាន នៃគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រង់ចំណុចនេះ។ នៅក្នុងស្ថានភាពទាំងអស់នោះ ជនជាប់ចោទបានតវ៉ាថា វិធាន ២១(១) នៃវិធានផ្ទៃក្នុង តម្រូវឲ្យតុលាការនេះបកស្រាយវិធានផ្ទៃជា

[159] របាយការណ៍របស់អគ្គលេខា កថាខណ្ឌ ២៩, ៣៥, ៤០-៤២។ អត្ថបទរបស់ Scheffer ទំព័រ ២៤៥-២៤៧។

[160] *សូមមើល, ឧទាហរណ៍* ឯកសារ **D257/1/8** សេចក្តីពិចារណាលើសំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។ ឯកសារ **D263/1/5** សេចក្តីពិចារណាលើសំណើសុំរបស់ អោ អាន សុំមោឃភាពកិច្ចស៊ើបអង្កេតទាក់ទងនឹងវត្តតាមាក់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។ ឯកសារ **D299/3/2** សេចក្តីពិចារណាលើសំណើរបស់ អោ អាន សុំអង្គបុរេជំនុំជម្រះ ទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦។

[161] អត្ថបទរបស់ Scheffer ទំព័រ២៤៦។

[162] *សូមមើល* ឯកសារ **D359/3/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០០-១០៨។

[163] *ផ្ទុយពីនេះ* **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៦៥, ៦៧។

ប្រយោជន៍របស់ពួកគេ ដើម្បីការពារផលប្រយោជន៍របស់ពួកគេ ប៉ុន្តែ អ.ជ.ត.ក បានសម្រេចថា វិធីបកស្រាយវិធានផ្ទៃក្នុង "មិនមានន័យថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ"។ ការពិចារណាដែលពាក់ព័ន្ធនោះគឺថា ការបកស្រាយនេះមិនរំលោភលើសិទ្ធិជាមូលដ្ឋានណាមួយរបស់ជនជាប់ចោទ[164]។

51. ហេតុដូច្នេះ ការបកស្រាយរបស់ ស.ព.អ មិនរំលោភសិទ្ធិជាមូលដ្ឋានរបស់ អោ អាន ក្នុងការទទួលបានសច្ចធារណ៍នៃនិរទោស ដូចដែល អោ អាន បានអះអាងនោះឡើយ[165]។ សច្ចធារណ៍នៃនិរទោសធានាថា មុនពេលកំណត់ការផ្តន្ទាទោសព្រហ្មទណ្ឌ អយ្យការមានកាតព្វកិច្ចបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ឲ្យហួសពីវិមតិសង្ស័យ *នៅពេលជំនុំជម្រះ*[166]។ ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទទាំងអស់ រួមទាំង អោ អាន ផង ទទួលបានសច្ចធារណ៍នៃនិរទោសនេះលុះត្រាតែ និង រហូតទាល់តែពួកគេត្រូវបានផ្តន្ទាទោសដោយចៅក្រមភាគច្រើនលើស លប់នៃអង្គជំនុំជម្រះសាលាដំបូង។

## IV. ដំណោះស្រាយដែលស្នើឡើង

52. ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដោយគោរពឲ្យអង្គបុរេជំនុំជម្រះបដិសេធការសន្និដ្ឋានខុសរបស់ដីកាសម្រេចលើកលែងចោទ

[164] *សូមមើល ឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **E50/2/1/4** សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩។ សំណុំរឿង០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣០ *សូមមើលផងដែរ* កថាខណ្ឌ៣១។ សំណុំរឿង០០២-ឯកសារ **E154/1/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ១៤។

[165] ឯកសារ **D359/3/4** ចម្លើយតបរបស់ អោ អាន កថាខណ្ឌ ៦៥, ៦៧។

[166] *សូមមើល, ឧទាហរណ៍* ច្បាប់ អ.វ.ត.ក មាត្រា ៣៥ថ្មី។ វិធាន ២១ នៃវិធានផ្ទៃក្នុង។ *រដ្ឋអាជ្ញា ទល់នឹង Kayishema & Ruzindana*, ICTR-95-1-A សាលដីកា (សំអាងហេតុ) អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១០៧។ សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ខុច* កថាខណ្ឌ ៣៣។

ប្រកាន់ ដែលថា អោ អាន មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ស្នើសុំឱ្យ អ.ប.ជ សម្រេចថា អោ អាន គឺជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងស្នើឱ្យបញ្ជូន អោ អាន ទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ | **លោក Nicholas KOUMJIAN**<br>**សហព្រះរាជអាជ្ញា**អន្តរជាតិ | ភ្នំពេញ | |